# មាតិកា

## I~ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ

១៧-៧-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៧០៥/៣២៤ ស្តីពីការតែងតាំងឯកឧត្តម **កង ស៊ីថន** ជាទីប្រឹក្សាសម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ទទួលបន្ទុកការងារ ទេសចរណ៍ និង សណ្ឋាគារ មានឋានៈស្មើ **រដ្ឋលេខាធិការ** ដោយពុំទទួលប្រាក់បៀវត្ស ៤៥៧២

២៣-៧-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៧០៥/៣២៥ ស្តីពីការតែងតាំងឯកឧត្តមចំនួន ០២ រូប ជាសមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ៤៥៧៣

២៣-៧-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៧០៥/៣២៧ ស្តីពីការតម្លើងឋានៈជូនឯកឧត្តមអគ្គលេខាធិការរងរាជរដ្ឋាភិបាល ចំនួន ០២ រូប មានឋានៈស្មើ **រដ្ឋលេខាធិការ** ៤៥៧៤

២៣-៧-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៧០៥/៣២៨ ស្តីពីការតែងតាំងឯកឧត្តម **នាង មុត** ជាទីប្រឹក្សាក្រសួងអប់រំ យុវជន និងកីឡា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ៤៥៧៥

## II~ក្រុមប្រឹក្សាធម្មនុញ្ញ

២៧-៧-២០០៥ -សេចក្តីសំរេចលេខ ០៧២/០០៤/២០០៥ កបធ.ច ចុះថ្ងៃទី២៧ខែ កក្កដា ឆ្នាំ ២០០៥ ៤៥៧៦

## III~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ

២៥-៧-២០០៥ -អនុក្រឹត្យលេខ ៩២ អនក្រ.បក ស្តីពីការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃទីស្តីការគណៈរដ្ឋមន្ត្រី ៤៥៧៨

២៧-៧-២០០៥ -អនុក្រឹត្យលេខ ៩៣ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៤៥៨០

២៧-៧-២០០៥ -អនុក្រឹត្យលេខ ៩៤ អនក្រ.បក ស្តីពីការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃ ក្រសួងអប់រំ យុវជន និងកីឡា ៤៥៨២

២៥-៧-២០០៥ -អនុក្រឹត្យលេខ ៦០៦ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៤៥៨៤

២៥-៧-២០០៥ -អនុក្រឹត្យលេខ ៦០៧ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៤៥៨៥

២៥-៧-២០០៥ -អនុក្រឹត្យលេខ ៦០៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤៥៨៦

២៥-៧-២០០៥ -អនុក្រឹត្យលេខ ៦០៩ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៤៥៨៧

២៥-៧-២០០៥ -អនុក្រឹត្យលេខ ៦១០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤៥៨៨

២៥-៧-២០០៥ -អនុក្រឹត្យលេខ ៦១១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤៥៨៩

២៥-៧-២០០៥ -អនុក្រឹត្យលេខ ៦១២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤៥៩០

២៥-៧-២០០៥ -អនុក្រឹត្យលេខ ៦១៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤៥៩២

២៥-៧-២០០៥ -អនុក្រឹត្យលេខ ៦១៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤៥៩៤

២៥-៧-២០០៥ -អនុក្រឹត្យលេខ ៦១៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤៥៩៦

២៥-៧-២០០៥ -អនុក្រឹត្យលេខ ៦១៦ អនក្រ.តត ស្តីពីការតម្លើងថ្នាក់ក្នុងឋានន្តរស័ក្តិវរមន្ត្រី ជូនមន្ត្រីរាជការនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ ៤៥៩៨

២៦-៧-២០០៥ -អនុក្រឹត្យលេខ ៦១៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤៦០០

២៦-៧-២០០៥ -អនុក្រឹត្យលេខ ៦១៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤៦០២

២៦-៧-២០០៥ -អនុក្រឹត្យលេខ ៦១៩ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៤៦០៣

២៧-៧-២០០៥ -អនុក្រឹត្យលេខ ៦២០ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិ នាយអាវុធហត្ថជាតិ ៤៦០៤

២៧-៧-២០០៥ -អនុក្រឹត្យលេខ ៦២១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤៦០៦

២៧-៧-២០០៥ -អនុក្រឹត្យលេខ ៦២២ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៤៦០៨

២៨-៧-២០០៥ -អនុក្រឹត្យលេខ ៦២៣ អនក្រ.តត ស្តីពីការផ្ទេរភារកិច្ចនិងផ្លាស់ប្តូរមុខងារនាយទាហាន ៤៦០៩

២៨-៧-២០០៥ -អនុក្រឹត្យលេខ ៦២៤ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៤៦១០

២៨-៧-២០០៥ -អនុក្រឹត្យលេខ ៦២៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤៦១១

២៨-៧-២០០៥ -អនុក្រឹត្យលេខ ៦២៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤៦១២

២៨-៧-២០០៥ -អនុក្រឹត្យលេខ ៦២៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤៦១៤

២៨-៧-២០០៥ -អនុក្រឹត្យលេខ ៦២៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤៦១៥

២៨-៧-២០០៥ -អនុក្រឹត្យលេខ ៦២៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤៦១៦

២៩-៧-២០០៥ -អនុក្រឹត្យលេខ ៦៣០ អនក្រ.តត ស្តីពីការតែងតាំង និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៤៦១៨


## ២_សេចក្តីសំរេច


២៦-៧-២០០៥ -សេចក្តីសំរេចលេខ ២៥ សសរ ស្តីពីការបង្កើតលេខាធិការដ្ឋានគណៈកម្មាធិការជាតិដឹកនាំបញ្ជាប្រយុទ្ធ និងទប់ស្កាត់អំពើភេរវកម្ម ៤៦២០

២៧-៧-២០០៥ -សេចក្តីសំរេចលេខ ២៦ សសរ ស្តីពី ការកែសម្រួលសមាសភាពនៃក្រុមការងារសំរាប់បំភ្លឺទៅនឹងមតិជំទាស់ជាមួយនយោបាយដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ៤៦២៦

## ៣-សារាចរណែនាំ

១៥-៧-២០០៥ -សារាចរណែនាំលេខ ០៦ សរណន ស្តីពីការអនុវត្តគំរោងរបស់អង្គការពលកម្មអន្តរជាតិ ដើម្បីធ្វើឱ្យប្រសើរឡើងវិញដល់រោងចក្រកម្ពុជាក្នុងវិស័យវាយនភ័ណ្ឌនិងសំលៀកបំពាក់ ៤៦២៧

## IV-ការិយាល័យក្រសួង

## ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

២៥-៧-២០០៥ -ប្រកាសលេខ ៨៩៧ ប្រក ស្តីពីការលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ៤៦៣០

## ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

០៤-៧-២០០៥ -លិខិតលេខ ១៥៣៤ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ជេ.ស៊ី.ធី** ៤៦៣១

០៥-៧-២០០៥ -លិខិតលេខ ១៥៤០ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ហ្វ្រ៊ីន រ៉េនបូ ស៊ីទីស** ៤៦៣៣

០៥-៧-២០០៥ -លិខិតលេខ ១៥៤១ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **លី បេស ខនស្ត្រាក់សិន** ៤៦៣៥

០៥-៧-២០០៥ -លិខិតលេខ ១៥៥២ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **មើត ហ្គាមេន** ៤៦៣៧

០៥-៧-២០០៥ -លិខិតលេខ ១៥៥៣ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **យឹង ហ្វេសិន ហ្គាមេន** ៤៦៣៨

០៥-៧-២០០៥ -លិខិតលេខ ១៥៦២ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ជ្រួន ស៊ីវខេង គ្រុប** ៤៦៣៩

០៥-៧-២០០៥ -លិខិតលេខ ១៥៦៤ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ប្លូសឹម អូស្ត្រាលី & (ខេមបូឌា) អ៊ិមផត អិចផត** ៤៦៤១

០៥-៧-២០០៥ -លិខិតលេខ ១៥៦៦ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ឆាយណា ស្យុង ស៊ូ (ខេមបូឌា)** ៤៦៤៣

០៦-៧-២០០៥ -លិខិតលេខ ១៥៦៨ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ធី . វឌ្ឍនា (ខេមបូឌា)** ៤៦៤៥

០៦-៧-២០០៥ -លិខិតលេខ ១៥៧៥ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **សេក សោម** ៤៦៤៧

០៦-៧-២០០៥ -លិខិតលេខ ១៥៧៦ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ម៉ូ មីយុង ត្រាយអ៊ែងហ្គល អ៊ិនជាសស្ត្រី ខបភើរេសិន** ៤៦៤៩

០៦-៧-២០០៥ -លិខិតលេខ ១៥៨១ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**បូរ៉ាផា ធីត អ៊ិនវេសមេន** ៤៦៥១

០៧-៧-២០០៥ -លិខិតលេខ ១៥៨៧ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ឆឹង ថៃ** ៤៦៥៣

០៧-៧-២០០៥ -លិខិតលេខ ១៥៨៨ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**វើលដ៍ វ៉ាយដ៍ មេនផៅវ័រ (ដាប់បែលយូ ដាប់បែលយូ អ៊ិម ស៊ី)** ៤៦៥៥

០៧-៧-២០០៥ -លិខិតលេខ ១៥៩០ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ត្រាស្ទី ខាសស្ដ៏មស៍ ឃ្លារេនស៍ អិលធីឌី** ៤៦៥៧

០៧-៧-២០០៥ -លិខិតលេខ ១៥៩៣ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**វ៉ាង ថ អ៊ិមផត អិចផត** ៤៦៥៩

០៧-៧-២០០៥ -លិខិតលេខ ១៥៩៥ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អាយ យ្សូ អូ ខេ** ៤៦៦១

០៧-៧-២០០៥ -លិខិតលេខ ១៥៩៦ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ឈន ឈិន ឌីវេឡុបមេន (ខេមបូឌា)** ៤៦៦៣

០៨-៧-២០០៥ -លិខិតលេខ ១៥៩៧ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ខេ.ស៊ី.អិល.អេស** ៤៦៦៥

០៨-៧-២០០៥ -លិខិតលេខ ១៥៩៨ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ពៅ គីមឡេង** ៤៦៦៧

០៨-៧-២០០៥ -លិខិតលេខ ១៥៩៩ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ស៊ី.អេជ.ស៊ី.លីមីធីត** ៤៦៦៩

០៨-៧-២០០៥ -លិខិតលេខ ១៦០០ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ស៊ីប៊ីអាយអំរឌី មីក្រូហិរញ្ញវត្ថុ លីមីធីត** ៤៦៧០

០៨-៧-២០០៥ -លិខិតលេខ ១៦០១ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**វ៉ា វ៉ាង (ខេមបូឌា) ប្រូដាក់ អ៊ិនវេសមេន ខូ អិលធីឌី** ៤៦៧២

០៨-៧-២០០៥ -លិខិតលេខ ១៦០២ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ឆាយណា ហេង ហេង ខូ អិលធីឌី** ៤៦៧៤

០៨-៧-២០០៥ -លិខិតលេខ ១៦០៣ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អុីភី ឡូជីស្ទិក** ៤៦៧៦

០៨-៧-២០០៥ -លិខិតលេខ ១៦០៤ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**បេសវេយ អុិនដាសស្ត្រាល** ៤៦៧៨

០៨-៧-២០០៥ -លិខិតលេខ ១៦០៥ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អូស៊ីន ឃីង (ខេមបូឌា)** ៤៦៧៩

០៨-៧-២០០៥ -លិខិតលេខ ១៦១០ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**នីអូខម គ្រុប អុិនវេសមេន លីមីធីត** ៤៦៨០

០៨-៧-២០០៥ -លិខិតលេខ ១៦១១ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ហ្គោលដេន អុីតា ត្រេឌីង** ៤៦៨២

០៨-៧-២០០៥ -លិខិតលេខ ១៦១៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ហ្គោល វ៉ាន់ ឡុង** ៤៦៨៤

១១-៧-២០០៥ -លិខិតលេខ ១៦១៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អិល.ភី.អ អុីមផត អិចផត** ៤៦៨៦

១១-៧-២០០៥ -លិខិតលេខ ១៦១៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ងីម សៀង ប្រូឌុស អុីមផត អិចផត** ៤៦៨៨

១១-៧-២០០៥ -លិខិតលេខ ១៦១៧ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អូ អេស ភី ខូ អិលធីឌី** ៤៦៩០

១១-៧-២០០៥ -លិខិតលេខ ១៦១៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**មាស សុខ ហេង** ៤៦៩២

១១-៧-២០០៥ -លិខិតលេខ ១៦២៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អីមស៊ីស៊ីម ខបភើរេសិន អិលធីឌី** ៤៦៩៤

១១-៧-២០០៥ -លិខិតលេខ ១៦២៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អាទប្ប មីស៊ីណារី & អេឡិកទ្រិក (ខេមបូឌា)** ៤៦៩៦

១២-៧-២០០៥ -លិខិតលេខ ១៦៣០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**បាធីម៉ិចក្ខ អុីមផត អិចផត** ៤៦៩៨

១២-៧-២០០៥ -លិខិតលេខ ១៦៣១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ហ្វូទូន ហ្វូលឌីង ខមភេនី** ៤៧០០

១២-៧-២០០៥ -លិខិតលេខ ១៦៣២ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ស៊ីហា អភិវឌ្ឍន៍ (កម្ពុជា)** ៤៧០២

១៣-៧-២០០៥ -លិខិតលេខ ១៦៣៥ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ស្ទីង សន្ថៃ ខូ អិលធីឌី** ៤៧០៤

១៣-៧-២០០៥ -លិខិតលេខ ១៦៣២ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ជាដា ខបភើរេសិន ភីធីអ៊ី អិលធីឌី** ៤៧០៦

# ព្រះរាជក្រឹត្យ

នស/រកត/០៧០៥/៣២៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរិវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់រដ្ឋធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចប្រធានព្រឹទ្ធសភា

## ត្រាស់បង្គាប់

**មាត្រា ១:** តែងតាំងឯកឧត្តម **គង់ ស៊ីថន** ជាទីប្រឹក្សាសម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ទទួលបន្ទុកការងារ ទេសចរណ៍ និងសណ្ឋាគារ មានឋានៈស្មើ **រដ្ឋលេខាធិការ** ដោយពុំទទួលប្រាក់បៀវត្ស ។

**មាត្រា ២:** ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល.០៥០៧.៣៤៥

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៥

លេខ: ២៩៧. ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ២០០៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**[illegible] តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០៧០៥/៣២៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**

**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**

**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតែងតាំងជាសមាជិកក្រុមប្រឹក្សាអ្នកច្បាប់ដែលមានសមាសភាព :

១-ឯកឧត្តម **ញ៉ែម សុភក្ត្រា** ជាសមាជិក មានឋានៈស្មើអនុរដ្ឋលេខាធិការ

២-ឯកឧត្តម **ឃាង សេង** ជាសមាជិកបម្រុង មានឋានៈស្មើអគ្គនាយក។

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣៤ល-០៥០៧.៣៤៦

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០៥*

លេខ : ២៩៤ ច.ល

**ដើម្បីចម្លងចែកចាយ**

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ២០០៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**[illegible] តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០៧០៥/៣៧៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាស អោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១.-** ត្រូវបានតម្លើងឋានៈ ជូនឯកឧត្តម អគ្គលេខាធិការរងរាជរដ្ឋាភិបាល ចំនួន០២រូប ដូចមានរាយនាម ខាងក្រោម :

១-ឯកឧត្តម **ឃុន ជិនកេន** អគ្គលេខាធិការរងរាជរដ្ឋាភិបាល មានឋានៈស្មើ **រដ្ឋលេខាធិការ**

២-ឯកឧត្តម **ឆ័យ រឿន** អគ្គលេខាធិការរងរាជរដ្ឋាភិបាល មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

**មាត្រា២.-** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣.-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានបញ្ញត្តិ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល-០៥០៧.៣៤៨

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញថ្ងៃទី ៦៣ ខែ កក្កដា ឆ្នាំ ២០០៥

លេខ : ... ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ... ខែ កក្កដា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
ស៊ាន់ តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៧០៥/៣២៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : ត្រូវបានតែងតាំងឯកឧត្តម **នាង មុត** ជាទីប្រឹក្សាក្រសួងអប់រំ យុវជន និងកីឡា មានឋានៈស្មើអនុរដ្ឋលេខាធិការ ។

**មាត្រា២** : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រស.០៥០៧.៣៤៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០៥

លេខ ២៩៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
ស៊ីវ៉ាឌី តាន់

12

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**
លេខ : ០៩៨/០០៨/២០០៥
ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៥
**សេចក្ដីសម្រេច**
លេខ : ០៧២/០០៤/២០០៥ កបធ.ច
ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៥

## ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញលិខិតលេខ ២០២/០៧០៥/ពស/នវ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៥ របស់សម្ដេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ដែលស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យធម្មនុញ្ញភាពប្រការ ៤៤ ថ្មី នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៥

**ក្រោយពីបានស្ដាប់របាយការណ៍របស់សមាជិករាយការណ៍**
**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

-យល់ឃើញថា ការស្នើសុំឱ្យពិនិត្យធម្មនុញ្ញភាពប្រការ ៤៤ ថ្មី នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ដោយប្រធានព្រឹទ្ធសភា ជាការស្របនឹងរដ្ឋធម្មនុញ្ញ (ឃ្លាទី ១ វាក្យខ័ណ្ឌទី ២ នៃមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ)

-យល់ឃើញថា ការពិនិត្យ និងសម្រេចអំពីធម្មនុញ្ញភាពប្រការ ៤៤ ថ្មី នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ (ឃ្លាទី ២ វាក្យខ័ណ្ឌទី ២ នៃមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ)

-យល់ឃើញថា ប្រការ ៤៤ ថ្មី នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភានេះ ពុំមានអ្វីផ្ទុយនឹងមាត្រា ១១១ ថ្មី (មួយ) វាក្យខ័ណ្ឌទី ៣ នៃរដ្ឋធម្មនុញ្ញទេ

**សម្រេច**

**មាត្រា ១.-** ប្រការ ៤៤ ថ្មី នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ដែលព្រឹទ្ធសភាបានអនុម័តកាលពីថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៥ ត្រូវបាន**ប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ** ។

**មាត្រា ២.-** សេចក្ដីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្ដីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៥

ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ប៊ិន ឈិន

# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៩៦៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃទីស្តីការគណៈរដ្ឋមន្ត្រី

*********

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសវនកម្ម នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីរៀបចំ និងការប្រព្រឹត្តទៅ នៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

**មាត្រា១ :**

ត្រូវបានបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង ដែលចំណុះផ្ទាល់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការ-គណៈរដ្ឋមន្ត្រី ។

Sc 13-07-05

**មាត្រា២ :**

នាយកដ្ឋានសវនកម្មផ្ទៃក្នុង ទទួលបន្ទុកអនុវត្តភារកិច្ចតាមអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីរៀបចំ និងការប្រព្រឹត្តទៅ នៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាស្ថាប័នក្រសួង និងសហគ្រាសសាធារណៈ ។

នាយកដ្ឋានសវនកម្មផ្ទៃក្នុង ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួន ជាជំនួយការតាមការចាំបាច់ ។

វចនាសម្ព័ន្ធ ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋានសវនកម្មផ្ទៃក្នុង ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា៣ :**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៤ :**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

**សុខ អាន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម និងសម្តេចឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ដូចមាត្រា៤
- ឯកសារ កាលប្បវត្តិ

Sc 13-07-05

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៩៣ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ . ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧ . ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ . ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ . ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ . ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ .ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធ ហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ ន.ស ៩៤ . ចុះថ្ងៃទិ ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ . ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៤/០០២ . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៥
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក . ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ .បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែមនិងកែសំរួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៩២ អនក្រ.បក . ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៤ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋ តាមជំពូកនៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៥
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ៦២៥ លានរៀល ( ប្រាំមួយរយម្ភៃប្រាំលានរៀលគត់ ) ពី ជំពូក ៤១ ( ចំណាយមិនបានគ្រោងទុក ) នៃខ្ទង់ចំណាយមិនទាន់បែងចែកមកជំពូក១១ ( ចំណាយដំណើរការរដ្ឋបាលសំភារៈ និង ការជួសជុលតូច ) ជូនរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីរៀបចំសន្និសីទអាស៊ានលើកទី ១៣ ស្តីពីកិច្ចការមុខងារសាធារណៈ ឆ្នាំ ២០០៥ ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

**បានយកសេចក្តីជំរាបជូន**

**សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៩៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងអប់រំ យុវជន និងកីឡា

--------

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុង នៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## ស ម្រេ ច

**មាត្រា ១ :**

ត្រូវបានបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង ដែលចំណុះផ្ទាល់រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា ២ :**

នាយកដ្ឋានសវនកម្មផ្ទៃក្នុង ទទួលបន្ទុកអនុវត្តភារកិច្ចតាមអនុក្រឹត្យលេខ ៤០អនក្រ.បក ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុង នៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ ។

នាយកដ្ឋានសវនកម្មផ្ទៃក្នុង ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួន ជាជំនួយការតាមការចាំបាច់ ។

រចនាសម្ព័ន្ធ ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋានសវនកម្មផ្ទៃក្នុង ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៣ :**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤ :**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមហត្ថលេខា

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

**បណ្ឌិត គុល ផេង**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា៤
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៧០៤ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពត៌មាន
- បានឃើញអនុក្រឹត្យ លេខ ៧០ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពត៌មាន
- បានឃើញអនុក្រឹត្យ លេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពត៌មាន

## សម្រេច

**មាត្រា ១ :** ត្រូវបានប្រគល់ភារកិច្ចជូនលោក **សោម ឫទ្ធី** ឱ្យបំពេញមុខងារជាអគ្គនាយករង អគ្គនាយកដ្ឋានទីភ្នាក់ងារសារពត៌មានកម្ពុជា AKP នៃក្រសួងពត៌មាន ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពត៌មាន រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ [illegible] ឆ្នាំ ២០០៥

ហ៊ុន សែន

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៦០៧ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ០៧០៤ /១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិតសភាកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៥ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និងមាត្រា២០ នៃព្រះរាជក្រឹត្យស្តីពីការបង្កើតរាជបណ្ឌិតសភា
- បានឃើញអនុក្រឹត្យលេខ ៤៤ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់រាជបណ្ឌិតសភាកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៦ អនក្រ.បក ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០០ ស្តីពីបុព្វសិទ្ធិរបស់បុគ្គលិក និងសមាជិកនៃរាជបណ្ឌិតសភាកម្ពុជា
- យោងតាមសំណើរបស់ប្រធានរាជបណ្ឌិតសភាកម្ពុជា

## សម្រេច

**មាត្រា១:** តែងតាំង ឯកឧត្តម **ឡៅ ឈីវអ៊ាវ** ជាសមាជិកក្រុមប្រឹក្សាភិបាល នៃរាជបណ្ឌិតសភាកម្ពុជា បន្ថែមលើមុខងារបច្ចុប្បន្ន ជំនួសឯកឧត្តម **ពិត ចំណាន** ដែលត្រូវបានតែងតាំងជារដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា២:** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានរាជបណ្ឌិតសភាកម្ពុជា រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៥

ហ៊ុន សែន

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ:...៧០៨.....អនក្រ-បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

### សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេន និង ជូនសប្បុរសជន ចំនួន០៦រូប ដែលបានបរិច្ចាគបច្ច័យនិងថវិកា ចូលរួមជួយកសាងសមិទ្ធផលនានាជាច្រើន នៅក្នុងវត្តព្រែកប្រា សង្កាត់ព្រែកប្រា ខណ្ឌមានជ័យ រាជធានីភ្នំពេញ ដូចមានរាយ ព្រះនាមនិងនាមខាងក្រោម :-

១-ព្រះតេជគុណ **ខ្ញី ឃឿន** ចៅអធិការវត្តកាកធិញ ស្រុកច័ន្ទបុរី ប្រទេសថៃ បច្ច័យចំនួន ១៦.២០០ដុល្លារ

២-ព្រះតេជគុណ **ស៊ឹម មុនី** បច្ច័យចំនួន ១២.១៥៥ ដុល្លារ

៣-ព្រះតេជគុណ **ឃិន សុវណ្ណ** បច្ច័យចំនួន ១១.១៦៧ ដុល្លារ

៤-ព្រះតេជគុណ **យន សុមេធ** បច្ច័យចំនួន ១០.១៨០ ដុល្លារ

៥-លោក **ពៅ យាដា** ថវិកាចំនួន ១៣.២៥០ ដុល្លារ

៦-លោក **ឆេព ជុន** ថវិកាចំនួន ១០.២៥០ ដុល្លារ

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា និង អភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

PS68

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧០៩ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

**សម្រេច**

**មាត្រា១ :** ត្រូវបានបំពាក់ មេដាយ **មុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ប្រគេនព្រះតេជគុណ **គាន សុផាណារិទ្ធ** ព្រះចៅអធិការវត្តព្រែកប្រា ដែលមានស្នាព្រះហស្ត និងគុណបំណាច់ខ្ពស់ក្នុងការចូលរួមកសាងនិងអភិវឌ្ឍន៍ប្រទេសជាតិ លើវិស័យព្រះពុទ្ធសាសនា វិស័យអប់រំ ដោយបានបរិច្ចាគបច្ច័យ ចំនួន ៥២៥.៣៩៥ ដុល្លារអាមេរិក ជួយកសាងសមិទ្ធផលនានា ជាច្រើន នៅក្នុងពុទ្ធសីមាវត្តព្រែកប្រា សង្កាត់ព្រែកប្រា ខណ្ឌមានជ័យ រាជធានីភ្នំពេញ ព្រមទាំងបានផ្តល់អំណោយជាសំភារៈ ចែកជូនប្រជាពលរដ្ឋ ជាច្រើនទៀត ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា និង អភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ [illegible] ឆ្នាំ ២០០៥

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

PS67

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ:...៤១០...អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេនព្រះតេជគុណ **នៅ ម៉ុនធុល** ចៅអធិការវត្តបទុមសុរិយា ដែលបានខិតខំចលនាពុទ្ធបរិស័ទ ជួយជួសជុល សាងសង់ព្រះវិហារ កុដិ អគារពុទ្ធិកបឋមសិក្សា០១ខ្នង មាន០៣បន្ទប់ ធ្វើរបង ជីកស្រះទឹក និងសមិទ្ធផលផ្សេងៗទៀត នៅវត្តបទុមសុរិយា ឃុំពត់សរ ស្រុកបាទី ខេត្តតាកែវ អោយមានសោភណភាពសមរម្យឡើងវិញ ចំណាយអស់បច្ច័យសរុបចំនួន ២១១.៤៦៣.៤០០ រៀល និង ១.៦០០ ដុល្លារ ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស និងអភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ,ថ្ងៃទី ២៥ ខែ [illegible] ឆ្នាំ ២០០៥

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

Ps-120

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...៧១១...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៙

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន០៥គ្រឿង ប្រគេននិងជូនសប្បុរសជន ដែលបានបរិច្ចាគធានធានជួយកសាងសាលាធម្មសភា សាលាបាលី ស្រះទឹក ភ្លេងពិណពាទ្យ និងរបងវត្តឧទុម្ពរ ព្រមទាំងកសាងអាគារសិក្សា ០១ខ្នង មាន០៣បន្ទប់ នៅឃុំដើមឫស ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដូចមានព្រះនាមនិងនាមខាង ក្រោម :-

| | | | |
|---|---|---|---|
| ១-ព្រះតេជគុណ | **គ្រាំ សឿន** | ចៅអធិការវត្តឧទុម្ពរ | បច្ច័យចំនួន ១១.៧០០ ដុល្លារ |
| ២-លោក | **ទ្វី គុម** | នៅសហរដ្ឋអាមេរិក | ថវិកា ចំនួន ១៣.៨០០ ដុល្លារ |
| ៣-លោក | **ម៉ែន យ៉ាន** | នៅសហរដ្ឋអាមេរិក | ថវិកា ចំនួន ១៤.៩៥០ ដុល្លារ |
| ៤-លោក | **តាំង សេងឆេង** | នៅសហរដ្ឋអាមេរិក | ថវិកា ចំនួន ១២.៧០០ ដុល្លារ |
| ៥-លោកស្រី | **ទ្វី សុភាព** | នៅសហរដ្ឋអាមេរិក | ថវិកា ចំនួន ១២.៦៥០ ដុល្លារ |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្ត អនុក្រឹត្យ នេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
SR.76 -ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៦១៤ អនក្រ-បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលរាជធានីភ្នំពេញ

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេន និងជូនសប្បុរសជន នៅក្នុងនិងក្រៅប្រទេស ចំនួន២៩រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ដើម្បីចូលរួមកសាងព្រះវិហារ កុដិនិងរបង នៅវត្តទឹកថ្លា សង្កាត់ទឹកថ្លា រាជធានីភ្នំពេញ ដូចមានរាយព្រះនាម និងនាមខាងក្រោមនេះ :-

| | | | | |
|---|---|---|---|---|
| ១-ភិក្ខុ | **សេង** | **សយ** | គង់នៅសហរដ្ឋអាមេរិក | បច្ច័យចំនួន ២៨.៤០០ ដុល្លារ |
| ២-ឯកឧត្តម | **កែវ** | **តាំ** | | **ថវិកា ចំនួន** ១១.២០០ ដុល្លារ |
| ៣-លោកឧកញ៉ា | **ផុង** | **អ៊ុយឆាំង** | | **ថវិកា ចំនួន** ១០.២០០ ដុល្លារ |
| ៤-លោកយាយ | **ចែម** | **ម៉ាន់** | នៅសហរដ្ឋអាមេរិក | **ថវិកា ចំនួន** ១១.៥០០ ដុល្លារ |
| ៥-លោក | **ម៉ឺន** | **ម៉ានថា** | នៅសហរដ្ឋអាមេរិក | ថវិកា **ចំនួន** ១២.៥០០ ដុល្លារ |
| ៦-លោក | **សុត** | **បុណ្ណា** | នៅសហរដ្ឋអាមេរិក | ថវិកា **ចំនួន** ១៣.០០០ ដុល្លារ |
| ៧-លោក | **រាជ** | **គម្ពី** | នៅសហរដ្ឋអាមេរិក | ថវិកា ចំនួន ១០.០១០ ដុល្លារ |
| ៨-លោក | **ឡុញ** | **ប៉ិល** | នៅសហរដ្ឋអាមេរិក | ថវិកា **ចំនួន** ១០.០៥០ ដុល្លារ |
| ៩-អ្នកស្រី | **កែវ** | **ស៊ីណាន** | នៅសហរដ្ឋអាមេរិក | **ថវិកា ចំនួន** ១១.៥០០ ដុល្លារ |
| ១០-លោកតា | **សួរ** | **ហួន** | នៅសហរដ្ឋអាមេរិក | **ថវិកា ចំនួន** ១០.០៥០ ដុល្លារ |
| ១១-លោកតា | **មួង** | **ម៉ឺន** | នៅសហរដ្ឋអាមេរិក | **ថវិកា ចំនួន** ១០.១០០ ដុល្លារ |

| | | | | |
|---|---|---|---|---|
| ១២-លោកតា | អ៊ូ | អុន | នៅសហរដ្ឋអាមេរិក | ថវិកា ចំនួន ១០.០៣០ ដុល្លារ |
| ១៣-លោក | យ៉ឹម | សាវិន | នៅសហរដ្ឋអាមេរិក | ថវិកា ចំនួន ១០.០៥០ ដុល្លារ |
| ១៤-លោក | ថាំង | ឡោត | នៅសហរដ្ឋអាមេរិក | ថវិកា ចំនួន ១០.០១០ ដុល្លារ |
| ១៥-លោកយាយ | ស្វួន | រិម | នៅសហរដ្ឋអាមេរិក | ថវិកា ចំនួន ១០.៥០០ ដុល្លារ |
| ១៦-លោកយាយ | មី | សៀង | នៅសហរដ្ឋអាមេរិក | ថវិកា ចំនួន ១១.០០០ ដុល្លារ |
| ១៧-លោកយាយ | សា | សាវឿន | នៅសហរដ្ឋអាមេរិក | ថវិកា ចំនួន ១២.០០០ ដុល្លារ |
| ១៨-លោកយាយ | ជួន | សំអុល | នៅសហរដ្ឋអាមេរិក | ថវិកា ចំនួន ១៤.០០០ ដុល្លារ |
| ១៩-លោកតា | ឈាង | ម៉េង | នៅសហរដ្ឋអាមេរិក | ថវិកា ចំនួន ១១.៥០០ ដុល្លារ |
| ២០-លោក | អ៊ូ | ឈាង | នៅសហរដ្ឋអាមេរិក | ថវិកា ចំនួន ១០.០៥០ ដុល្លារ |
| ២១-នាង | ជុំ | ពី | នៅសហរដ្ឋអាមេរិក | ថវិកា ចំនួន ១០.៥០០ ដុល្លារ |
| ២២-លោកតា | ចាប | ឡេង | នៅសហរដ្ឋអាមេរិក | ថវិកា ចំនួន ១០.០២០ ដុល្លារ |
| ២៣-លោក | ចុំយ | ជ៉ាង | នៅសហរដ្ឋអាមេរិក | ថវិកា ចំនួន ១០.០០០ ដុល្លារ |
| ២៤-ឧបាសិកា | អៀប | ឆៃហុង | នៅសហរដ្ឋអាមេរិក | ថវិកា ចំនួន ១០.០២០ ដុល្លារ |
| ២៥-លោក | កេង | ហួរផេង | នៅសហរដ្ឋអាមេរិក | ថវិកា ចំនួន ១០.០១០ ដុល្លារ |
| ២៦-លោក | ស៊ុន | ឆាម | នៅសហរដ្ឋអាមេរិក | ថវិកា ចំនួន ១០.២០០ ដុល្លារ |
| ២៧-លោកតា | អ៊ុំ | សេង | | ថវិកា ចំនួន ១០.០០០ ដុល្លារ |
| ២៨-លោក | ម៉ោញ | សាគៀន | នៅសហរដ្ឋអាមេរិក | ថវិកា ចំនួន ១២.១០០ ដុល្លារ |
| ២៩-លោកតា | ជួន | យាន | នៅសហរដ្ឋអាមេរិក | ថវិកា ចំនួន ១៣.២០០ ដុល្លារ |

**មាត្រា២ៈ** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

Tha.13-14

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ៧១៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន១១រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងសមិទ្ធផលនានាជាច្រើន នៅក្នុងស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង ដូចមានរាយនាមខាងក្រោម :-

**ក-មេដាយមាសស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១-លោក | **គីម ខួន** | ថវិកាចំនួន | ១១.៧២០ ដុល្លារ |
| ២-លោកស្រី | **យូ លីម** | ថវិកាចំនួន | ១១.៣០០ ដុល្លារ |
| ៣-លោក | **កែវ សុខឃាង** | ថិកាចំនួន | ១០.៣០០ ដុល្លារ |
| ៤-លោក | **សួស សុវណ្ណ** | ថិកាចំនួន | ១១.០៦០ ដុល្លារ |
| ៥-ឯកឧត្តម | **គុយ ពុំ** | ថវិកាចំនួន | ២៣.៥០០ ដុល្លារ |
| ៦-លោក | **ញាណ ស្រស់** | ថិកាចំនួន | ២០.៤០០ ដុល្លារ |
| ៧-លោក | **ឆាង សុផល់** | ថវិកាចំនួន | ១២.៥០០ ដុល្លារ |
| ៨-លោក | **ទ្រី សុន្ធារ** | ថវិកាចំនួន | ២០.៤០០ ដុល្លារ |
| ៩-លោក | **សុខ លក្ខិណា** | ថវិកាចំនួន | ១៨.៥០០ ដុល្លារ |
| ១០-លោក | **សួស ហឿន** | ថវិកាចំនួន | ១០.០៥០ ដុល្លារ |

ខ-មេដាយសិរីវឌ្ឍស្ថាបនាជាតិ :

-លោក **ឡេង តាត់** ថវិកាចំនួន ៣.១៨១ ដុល្លារ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តស្វាយរៀង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ ២០០៥*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

-17

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ៦១៤ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ចំនួន១៦គ្រឿង ជូនសប្បុរសជន ដែលបានបរិច្ចាគធនធាន ជួយកសាងសមិទ្ធផលផ្សេងៗ នៅវត្តត្រពាំងអំពិល ក្នុងឃុំជ្រៃវៀន ស្រុកព្រៃឈរ ខេត្តកំពង់ចាម ដូចមានរាយនាមខាងក្រោម :-

**ក.មេដាយមាសស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១-លោក | **គ្រី ឡុងហេង** | សប្បុរសជននៅខេត្តកំពង់ចាម | ថវិកាចំនួន ១០.៨០០ ដុល្លារ |
| ២-លោក | **ស្រី សារឿន** | អភិបាលស្រុកព្រៃឈរ | ថវិកាចំនួន ១០.៣០០ ដុល្លារ |

**ខ.មេដាយប្រាក់ស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១-លោក | **ស៊ឹម ចន្ថា** | សប្បុរសជននៅខេត្តកំពង់ចាម | ថវិកាចំនួន ៥.១០០ ដុល្លារ |
| ២-លោកតា | **នង ឆន** | សប្បុរសជននៅខេត្តកំពង់ចាម | ថវិកាចំនួន ៥.០០០ ដុល្លារ |
| ៣-លោកតា | **ឃុន ឃូ** | សប្បុរសជននៅខេត្តកំពង់ចាម | ថវិកាចំនួន ៥.០០០ ដុល្លារ |
| ៤-លោកយាយ | **ម៉ម ស៊ុនឡេង** | សប្បុរសជននៅខេត្តកំពង់ចាម | ថវិកាចំនួន ៥.០០០ ដុល្លារ |
| ៥-លោកយាយ | **ម៉ម ស៊ុនលី** | សប្បុរសជននៅខេត្តកំពង់ចាម | ថវិកាចំនួន ៥.០០០ ដុល្លារ |
| ៦-លោកតា | **គ្រី អេង** | សប្បុរសជននៅខេត្តកំពង់ចាម | ថវិកាចំនួន ៥.០០០ ដុល្លារ |

| | | | |
|---|---|---|---|
| ៧-លោក | នួន ម៉ុនធឿន | សប្បុរសជននៅខេត្តកំពង់ចាម | ថវិកាចំនួន ៥.០០០ ដុល្លារ |
| ៨-លោកតា | សោ ស៊ាម | សប្បុរសជននៅខេត្តកំពង់ចាម | ថវិកាចំនួន ៥.០០០ ដុល្លារ |
| ៩-លោក | ប្រាក់ ស៊ីន | សប្បុរសជននៅខេត្តកំពង់ចាម | ថវិកាចំនួន ៥.០០០ ដុល្លារ |

**គ-មេដាយសេរីវត្ថុស្ពាបនាជាតិ :**

| | | | |
|---|---|---|---|
| ១-លោក | នុត នាង | សប្បុរសជននៅខេត្តកំពង់ចាម | ថវិកាចំនួន ៣.០០០ ដុល្លារ |
| ២-លោកតា | ស៊ុំ មឿន | សប្បុរសជននៅខេត្តកំពង់ចាម | ថវិកាចំនួន ៣.០០០ ដុល្លារ |
| ៣-លោកតា | ញាន ព្រិច | សប្បុរសជននៅខេត្តកំពង់ចាម | ថវិកាចំនួន ៣.០០០ ដុល្លារ |
| ៤-លោកតា | អ៊ុំ ថេង | សប្បុរសជននៅខេត្តកំពង់ចាម | ថវិកាចំនួន ៣.០០០ ដុល្លារ |
| ៥-លោកតា | ឆៀង គុន | សប្បុរសជននៅខេត្តកំពង់ចាម | ថវិកាចំនួន ៣.០០០ ដុល្លារ |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យ នេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:......៦១៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៚

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ចំនួន១៦គ្រឿង ប្រគេននិងជូនសប្បុរសជន ដែលបានបរិច្ចាគធនធាន ជួយកសាងសមិទ្ធផលនានា ក្នុងវត្តពាមតាឯក ស្ថិតនៅក្នុងឃុំពាមឧកញ៉ាអុង ស្រុកល្វាឯម ខេត្តកណ្តាល ដូចមានរាយព្រះនាម និងនាមខាងក្រោម :-

**ក-មេដាយមាសស្ថាបនាជាតិ :**

១-ព្រះតេជគុណ **តឿន សាន** ចៅអធិការស្តីទី វត្តពាមតាឯក បច្ច័យចំនួន ១០.៥០០ ដុល្លារ

២-លោកវរសេនីយ៍ឯក **ហ៊ីម សារ៉ាន់** និងភរិយា មន្ត្រីយោធានៅក្រុងភ្នំពេញ ថវិកាចំនួន ៣៥.០០០ ដុល្លារ

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

១-ឯកឧត្តមទេសរដ្ឋមន្ត្រី **ហុង ស៊ុនហួត** សប្បុរសជននៅក្រុងភ្នំពេញ ថវិកាចំនួន ៥.០០០ ដុល្លារ

២-លោក **ណា ជំរ** សប្បុរសជននៅក្រុងភ្នំពេញ ថវិកាចំនួន ៥.០០០ ដុល្លារ

៣-លោក **ខៀវ ហួត** សប្បុរសជននៅក្រុងភ្នំពេញ ថវិកាចំនួន ៥.០០០ ដុល្លារ

**គ-មេដាយសំរឹទ្ធស្ថាបនាជាតិ :**

១-លោក **ព្រំ ហូ** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកាចំនួន ៣.០០០ ដុល្លារ

២-លោក **សួស វណ្ណសក្តិ** សប្បុរសជននៅក្រុងភ្នំពេញ ថវិកាចំនួន ២.០០០ ដុល្លារ

៣-លោក **អាង អ៊ឹម** អាចារ្យវត្តពាមតាឯក ថវិកាចំនួន ២.០០០ ដុល្លារ

៤-លោក **សំ គង់** អាចារ្យវត្តពាមតាឯក ថវិកាចំនួន ១.០០០ ដុល្លារ

| | | | | |
|---|---|---|---|---|
| ៥-លោក | **ឃឹម** | **រុន** | អាចារ្យវត្តពាមតាឯក | ថវិកាចំនួន ១.០០០ ដុល្លារ |
| ៦-លោក | **ហ៊ិន** | **សុខ** | គណៈកម្មការវត្តពាមតាឯក | ថវិកាចំនួន ១.០០០ ដុល្លារ |
| ៧-លោក | **ប៊ូ** | **សុត** | គណៈកម្មការវត្តពាមតាឯក | ថវិកាចំនួន ១.០០០ ដុល្លារ |
| ៨-លោក | **សុខ** | **ឡូត** | គណៈកម្មការវត្តពាមតាឯក | ថវិកាចំនួន ១.០០០ ដុល្លារ |
| ៩-លោក | **ជា** | **ស** | គណៈកម្មការវត្តពាមតាឯក | ថវិកាចំនួន ១.០០០ ដុល្លារ |
| ១០-លោក | **ឈឹម** | **ឈន** | គណៈកម្មការវត្តពាមតាឯក | ថវិកាចំនួន ១.០០០ ដុល្លារ |
| ១១-លោក | **ឌា** | **ឈុនហុក** | សប្បុរសជននៅក្រុងភ្នំពេញ | ថវិកាចំនួន ១.១០០ ដុល្លារ |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០៥*

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៦១៦ អនក្រ.តត

# អនុក្រឹត្យ
## ស្ដីពីការតម្លើងថ្នាក់
## ក្នុងឋានន្តរស័ក្តិវរមន្ត្រី ជូនមន្ត្រីរាជការនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់

* * * * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ ។
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

## សំរេច

**មាត្រា ១.—**

ត្រូវបានតម្លើងថ្នាក់ក្នុងឋានន្តរស័ក្តិវរមន្ត្រី ជូនមន្ត្រីរាជការនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដូចមានរាយនាមខាងក្រោម ៖

| | | | |
|---|---|---|---|
| ១ | លោក **សុខ សោភ័ណ** | ពីវរមន្ត្រី ថ្នាក់លេខ ៥ | ទៅថ្នាក់លេខ ៤ |
| ២ | លោក **អោក ទើត** | ពីវរមន្ត្រី ថ្នាក់លេខ ៥ | ទៅថ្នាក់លេខ ៤ |
| ៣ | លោក **សៀង រដ្ឋចារី** | ពីវរមន្ត្រី ថ្នាក់លេខ ៨ | ទៅថ្នាក់លេខ ៧ |
| ៤ | លោក **ណៃ ម៉េងអ៊ាង** | ពីវរមន្ត្រី ថ្នាក់លេខ ៨ | ទៅថ្នាក់លេខ ៧ |
| ៥ | លោក **ហោ មុនីរត្ន** | ពីវរមន្ត្រី ថ្នាក់លេខ ៨ | ទៅថ្នាក់លេខ ៧ |
| ៦ | លោក **ឆូន សែ** | ពីវរមន្ត្រី ថ្នាក់លេខ ៨ | ទៅថ្នាក់លេខ ៧ |

**មាត្រា ២.—**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣.—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋលេខាធិការនៃរដ្ឋលេខាធិកាដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ កក្កដា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល** :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា "៣"*
- *ឯកសារ - កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ:.....៧១៧.....អនក្រ-បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ
## ---
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន០៥រូប ដែលបានបរិច្ចាគធនធានជួយកសាង សាលាធម្មសភា ០១ខ្នង និង ផ្លូវលំចូលវត្ត ០១ខ្សែ នៅវត្តយសមន្ត្រី ឃុំប្រភ្នំ ស្រុកអង្គរជ័យ ខេត្តកំពត ដូចមានរាយនាមខាងក្រោមនេះ :-

**ក_មេដាយមាសស្ថាបនាជាតិ :**

១-ឧបាសិកា **ឯក សុន** នៅសហរដ្ឋអាមេរិក ថវិកាចំនួន ១២.០០០ ដុល្លារ

២-ពុទ្ធបរិស័ទ ក្នុងឃុំប្រភ្នំ ថវិកាចំនួន ១០.៨៥០ ដុល្លារ

៣-លោក **សួន ម៉ុនថន** និងលោកស្រី **ឃុត ណារ៉ាត់** នៅសហរដ្ឋអាមេរិក ថវិកាចំនួន ១០.០០០ ដុល្លារ

**ខ_មេដាយសំរឹទ្ធស្ថាបនាជាតិ :**

១-លោក **ស្វាយ នាក់** និងអ្នកស្រី **ណុប ណួន** នៅសហរដ្ឋអាមេរិក ថវិកាចំនួន ៣.៣០០ ដុល្លារ

២-លោកយាយ **យ៉ន មុំ , យ៉ន ម៉ុល , យ៉ន យេន** នៅប្រទេសអូស្ត្រាលី ថវិកាចំនួន ៣.៣០០ ដុល្លារ

៣-លោក **យី ប៉ៃ** និង ភរិយា នៅសហរដ្ឋអាមេរិក ថវិកាចំនួន ២.៤៥៥ ដុល្លារ
៤-លោកស្រី **ឃុត សុភឿន** និង ស្វាមី នៅសហរដ្ឋអាមេរិក ថវិកាចំនួន ១.៤៤៥ ដុល្លារ
៥-ឧបាសិកា **កុយ យេត** នៅក្រុងភ្នំពេញ ថវិកាចំនួន ១.៣៥០ ដុល្លារ
៦-ឧបាសក **ឧន់ ណាន** និង ឧបាសិកា **អ៊ឹ តែ** នៅខេត្តកំពត ថវិកាចំនួន ១.១៥០ ដុល្លារ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកំពត ត្រូវអនុវត្ត អនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ៧ ឆ្នាំ ២០០៥*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...៤១៧...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្រេច**

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេន និង ជូនសប្បុរសជន ចំនួន០២រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងអគារសិក្សា ០១ខ្នង មាន០៥បន្ទប់ បង្គន់អនាម័យ ០៥បន្ទប់ និង ទីចាត់ការ ០១ខ្នង នៅសាលាបឋមសិក្សា នន្ទសិរិ ឃុំឬស្សីក្រោក ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ដូចមានរាយព្រះនាមនិងនាមខាងក្រោមនេះ :-

១-ព្រះតេជគុណ **នេព សៀង** គង់នៅប្រទេសបារាំង បច្ច័យ ១៣.០២៥ ដុល្លារ

២-លោក **ឈឹម យ៉យ** និងលោកស្រី **ខំា ឡា** សប្បុរសជនខ្មែរនៅប្រទេសបារាំង ថវិកា ១៣.០២៥ ដុល្លារ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តបន្ទាយមានជ័យ ត្រូវ អនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

PS53

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៤១៩ អនក្រ. តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

**សម្រេច**

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **សេនា** ជូន លោក **Viacheslav DUNAEV** លេខាទី១ នៃអគ្គរដ្ឋទូតសហព័ន្ធរុស្ស៊ី ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលមានស្នាដៃល្អក្នុងកិច្ចសហប្រតិបត្តិការជួយបណ្តុះបណ្តាលធនធាន នគរបាលជាតិកម្ពុជា លើវិស័យការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

Ps-116

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៦៤០ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតម្លើងឋានន្តរស័ក្តិ នាយអាវុធហត្ថ
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់ អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការកែសំរួលរចនាសម្ព័ន្ធ និង ប្តូរឈ្មោះខុទ្ទកាល័យ ក្រសួងការពារជាតិ មកជាអគ្គលេខាធិការដ្ឋាន ក្រសួងការពារជាតិ
- យោងតាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

## ស ម្រេ ច

**មាត្រា១** : ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** នាយអាវុធហត្ថ ដែលមានរាយនាមដូចខាងក្រោម ÷

| | | | |
|---|---|---|---|
| ១-វរសេនីយ៍ទោ | **ហ៊ាន់ ណាឡូច** | អត្តលេខ ០០២៣០៩ | នាយករង សាលាកងរាជអាវុធហត្ថកំបូល |
| ២-វរសេនីយ៍ទោ | **ឡៀប ប៊ុនខេច** | អត្តលេខ ០០៤២៤៦ | នាយការិយាល័យអភិវឌ្ឍន៍ កងរាជអាវុធហត្ថលើផ្ទៃប្រទេស |
| ៣-វរសេនីយ៍ទោ | **ខៀប សាម៉េត** | អត្តលេខ ០០១៧៣២ | នាយខុទ្ទកាល័យ កងរាជអាវុធហត្ថលើផ្ទៃប្រទេស |
| ៤-វរសេនីយ៍ទោ | **ខៀប ស៊ីសាឌួន** | អត្តលេខ ០០២៥៤៧ | នាយករង សាលាហ្វឹកហ្វឺន កងរាជអាវុធហត្ថកំបូល |

៥-វរសេនីយ៍ទោ ទួន រត្ន័ឋាសនា អត្តលេខ ០០៨៧១៦ នាយករង សាលាហ្វឹកហ្វឺន
កងរាជអាវុធហត្ថកំបូល

៦-វរសេនីយ៍ទោ ឈាង សុខ អត្តលេខ ០០២៥៧២ មេបញ្ជាការ
កងរាជអាវុធហត្ថក្រុងប៉ៃលិន

៧-វរសេនីយ៍ទោ ស្រ៊ុន គឹមស្រៀង អត្តលេខ ០០៥១៦៥ នាយការិយាល័យបុគ្គលិក
កងរាជអាវុធហត្ថលើផ្ទៃប្រទេស

៨-វរសេនីយ៍ទោ ម៉ាន់ ប៉េងសៀង អត្តលេខ ០០៤២២៨ មេបញ្ជាការរង
កងរាជអាវុធហត្ថរាជធានីភ្នំពេញ

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៦៥៧ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពីការជូនមេដាយស្ថាបនាជាតិ**

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្រេច**

**មាត្រា១ៈ** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេននិងជូនសប្បុរសជន ចំនួន១៤រូបដែលបានបរិច្ចាគ ធនធានជួយកសាង ព្រះវិហារ សាលារៀន និង សមិទ្ធផលផ្សេងៗទៀត នៅវត្តស្រែកាន់ ឃុំទូកមាសខាងកើត ស្រុកបន្ទាយមាស ខេត្តកំពត ដូចមានរាយព្រះនាម និងនាមខាងក្រោមនេះ :-

**ក‿មេដាយមាសស្ថាបនាជាតិ :**

| | | | | |
|---|---|---|---|---|
| ១-ព្រះតេជគុណ | **ឃុត សុរដ្ឋា** | ចៅអធិការវត្តស្រែកាន់ | បច្ច័យចំនួន ១០.៦៩០ ដុល្លារ |
| ២-ឧបាសិកា | **សេង ឃុត** | សប្បុរសជននៅក្រុងភ្នំពេញ | ថវិកាចំនួន ១០.០៤០ ដុល្លារ |
| ៣-ឧបាសិកា | **ផេង និល** | សប្បុរសជននៅក្រុងភ្នំពេញ | ថវិកាចំនួន ១០.០៥០ ដុល្លារ |
| ៤-លោកជំទាវ | **ឡិម សាវី** | សប្បុរសជននៅខេត្តបាត់ដំបង | ថវិកាចំនួន ១០.៣៤៨ ដុល្លារ |
| ៥-លោកស្រី | **គីម មិក** | សប្បុរសជននៅខេត្តកំពត | ថវិកាចំនួន ១០.០១០ ដុល្លារ |
| ៦-លោកស្រី | **គីម បូ** | សប្បុរសជននៅក្រុងភ្នំពេញ | ថវិកាចំនួន ១០.០៣០ ដុល្លារ |
| ៧-លោកស្រី | **ចំរុង សុជាតា** | សប្បុរសជននៅក្រុងភ្នំពេញ | ថវិកាចំនួន ១០.១៦០ ដុល្លារ |
| ៨-លោក | **សោ ផុស** | សប្បុរសជននៅក្រុងភ្នំពេញ | ថវិកាចំនួន ១១.០០០ ដុល្លារ |

៩-លោក សេង គីម សប្បុរសជននៅខេត្តកំពត ថវិកាចំនួន ១០.៣០០ ដុល្លារ

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

១-លោកគ្រូ ស៊ីវ ម៉ូ សប្បុរសជននៅខេត្តកំពត ថវិកាចំនួន ៦.៥០០ ដុល្លារ

២-លោក គីម ម៉ិនធឿន សប្បុរសជននៅក្រុងព្រះសីហនុ ថវិកាចំនួន ៦.០៥៥ ដុល្លារ

៣-លោកស្រី កែម ម៉ុង សប្បុរសជននៅខេត្តកំពត ថវិកាចំនួន ៥.៨០០ ដុល្លារ

៤-លោកស្រី ជា សុចិន្តាមុនី សប្បុរសជននៅខេត្តកំពត ថវិកាចំនួន ៥.៥០០ ដុល្លារ

៥-លោកស្រី សែម សុគោល សប្បុរសជននៅខេត្តកំពត ថវិកាចំនួន ៥.៤៧០ ដុល្លារ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពត ត្រូវអនុវត្ត អនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ១២៤៧ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសុខាភិបាល

### សម្រេច

**មាត្រា១ៈ** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **ធិបឌិន្ទ** ជូនលោកវេជ្ជបណ្ឌិត **James Leonard Tulloch** តំណាងអង្គការសុខភាពពិភពលោក ដែលបានចូលរួមប្រយុទ្ធនឹងជំងឺ ហ៊ីវ - អេដស៍ - របេង គ្រុនចាញ់ ជំងឺសារ និង គ្រុនបក្សី ព្រមទាំងផ្នែកពង្រឹងប្រព័ន្ធសុខាភិបាល អភិវឌ្ឍន៍ធនធានមនុស្ស ការគ្រប់គ្រងឱសថ និង កម្មវិធីប្រឆាំងនឹងការជក់បារី ។

**មាត្រា២ៈ** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសុខាភិបាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

សម្តេច ហ៊ុន សែន

**កន្លែងទទួល** :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

B.Tha.37

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៦៧៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការផ្ទេរភារកិច្ចនិងផ្លាស់ប្តូរមុខងារ នាយទាហាន រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការកែសំរួលរចនាសម្ព័ន្ធ និង ប្តូរឈ្មោះខុទ្ទកាល័យ ក្រសួងការពារជាតិ មកជាអគ្គលេខាធិការដ្ឋាន ក្រសួងការពារជាតិ
- យោងតាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

## ស ម្រេ ច

**មាត្រា១** : ត្រូវបានផ្ទេរភារកិច្ច និងផ្លាស់ប្តូរមុខងារ នាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទជូន :

-ឯកឧត្តម ឧត្តមសេនីយ៍ឯក **ណឹម សុជាតិ** អត្តលេខ ០០០០៦៩ អគ្គនាយករង អគ្គនាយកដ្ឋានយោធសេវា បច្ចុប្បន្នជា អគ្គលេខាធិការរង អគ្គលេខាធិការដ្ឋាន ក្រសួងការពារជាតិ

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៦៧៤...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

៙៚

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តព្រៃវែង

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជនខ្មែរ ០១រូប និងជនជាតិជប៉ុន ០១រូប ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួន ជួយកសាងសមិទ្ធផលនានាជាច្រើន ដូចជា សាលារៀន អគារបណ្ណាល័យ ទីចាត់ការ អណ្តូងទឹក និង សំភារៈផ្សេងៗ ស្ថិតនៅក្នុងស្រុកពារាំង ខេត្តព្រៃវែង ដូចមានរាយនាមខាងក្រោម :-

**ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ :**

-លោក **ឡិក វិជ័យ** សប្បុរសជនខ្មែររស់នៅប្រទេសជប៉ុន ថវិកា ១៨៦.២០០ ដុល្លារ

**ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា :**

-លោក KUBOTA MITSUAKI ប្រធានសមាគម RISSHO KOSEIKAI ASHIKAGA YOUTH ប្រទេសជប៉ុន ថវិកា ១២១.១៤០ ដុល្លារ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។ 

រាជធានីភ្នំពេញ,ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
B.tha.23 -ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ៧៧៥ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៙៚

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តព្រៃវែង

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **YOSHIAKI SANADA** ជនជាតិជប៉ុន និងជានាយកសាកលវិទ្យាល័យ **Hoju Vocational . College** ប្រទេសជប៉ុន ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួន ជួយកសាងសមិទ្ធផលនានាជាច្រើន ដូចជាសាលារៀន អាគារបណ្ណាល័យ ទីចាត់ការ អណ្តូងទឹក និងសំភារៈផ្សេងៗ ស្ថិតនៅក្នុងស្រុកពារាំង ខេត្តព្រៃវែង ចំណាយអស់ថវិកា ចំនួន ១២.០០០ ដុល្លារអាមេរិក ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ... ខែ ... ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

B.tha.25

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧២៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន០៧រូប ដែលបានបរិច្ចាគធនធានជួយកសាងព្រះវិហារ សាលាធម្មសភា ព្រះពុទ្ធរូបអង្គធំ និង សមិទ្ធផលផ្សេងៗទៀត នៅវត្តទួលព្រះរាជា ឃុំពោធិបាន ស្រុកកោះធំ ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោម :-

១-ធម្មាចារ្យ **ឆាន ឧុទ្ធី** ប្រធានគណៈកម្មការវត្ត ថវិកាចំនួន ១១.៣៣០ ដុល្លារ

២-លោកជំទាវ **ម៉ែន សំអន** តំណាងរាស្ត្រមណ្ឌលស្វាយរៀង ថវិកាចំនួន ២៧.៣៥០ ដុល្លារ

៣-លោកជំទាវ **សោម គីមសួគ៌** តំណាងរាស្ត្រមណ្ឌលកំពត ថវិកាចំនួន ១៨.០៥០ ដុល្លារ

៤-ឯកឧត្តម **ប្រាក់ ហាម** រដ្ឋលេខាធិការក្រសួងទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច ថវិកាចំនួន ១៦.៤២០ ដុល្លារ

៥-លោក **សេខ នី** សប្បុរសជននៅសហរដ្ឋអាមេរិក ថវិកាចំនួន ១៣.៤១០ ដុល្លារ

៦-លោក **ជឹម គុនមេង** សប្បុរសជននៅសហរដ្ឋអាមេរិក ថវិកាចំនួន ១១.៨៦០ ដុល្លារ

៧-លោកស្រី **ហុក សាវី** សប្បុរសជននៅសហរដ្ឋអាមេរិក ថវិកាចំនួន ១០.៩០០ ដុល្លារ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៦៧៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៚

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** ចំនួន០៣គ្រឿង ប្រគេន និងជូនសប្បុរសជន ដែលបានបរិច្ចាគធនធាន ជួយកសាងអគារសិក្សា កុដិ និងសាលាភ័ត្ត នៅវត្តភ្នំខ្មែង ឃុំព្រៃស្វឹក ស្រុកទ្រាំង ខេត្តតាកែវ ដូចមានខាងក្រោម :-

**ក-មេដាយមាសស្ថាបនាជាតិ :**

-លោក **ច័ន្ទ ចិន** នៅខេត្តតាកែវ ថវិកា ចំនួន ១១.០០០ USD

**ខ-មេដាយសំរិទ្ធស្ថាបនាជាតិ :**

១-ព្រះតេជគុណ **ម៉ៅ សារ៉ែន** គង់នៅវត្តភ្នំខ្មែង បច្ច័យ ចំនួន ៣.៥០០ USD

២-លោក **ព្រហ្ម ណែត** នៅខេត្តតាកែវ ថវិកា ចំនួន ២.៣០០ USD

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

SR.84

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៤២៨ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **លី គឺនយុង** (*Mr.Lee Keun Young*) ប្រធានក្រុមហ៊ុន ***យូស៊ីន អេឡិចត្រូនិក កូអិលធីឌី*** (*Yushin Electronics Co LTD*) ដែលបានផ្តល់ថវិកា ចំនួន ១០.០០០ ដុល្លារសហរដ្ឋអាមេរិក ក្នុងបំណងជួយទ្រទ្រង់ដល់ សមាគមក្រុមបាល់ទាត់យុវជនកម្ពុជា ដើម្បីជំរុញការអភិវឌ្ឍន៍វិស័យកីឡាបាល់ទាត់ក្នុងក្របខ័ណ្ឌ នៃយុវជនកម្ពុជា ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យ នេះអោយទទួលបានលទ្ធផលល្អ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០៥*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

SK.18

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ៦៧៩ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និង ជូនសប្បុរសជន ចំនួន០៧រូប ដែលបាន បរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាងព្រះវិហារថ្មី នៅវត្តមណីភេត្រារាម ហៅ វត្តសំពៅ ឃុំស្វាយប៉ោ ស្រុកបាត់ដំបង ខេត្តបាត់ដំបង ដូចមានរាយព្រះនាមនិងនាមខាងក្រោមនេះ :-

**ក-មេដាយមាសស្ថាបនាជាតិ :**

១-ព្រះតេជគុណ **សំ សុធា** ចៅអធិការវត្ត សំពៅ បច្ច័យ ចំនួន ១០.០០០ ដុល្លារ
២-លោក **ចាន់ សុខឡុង** និងលោកស្រី **ឆួក ដារ៉ា** ថវិកា ចំនួន ២៨.០០០ ដុល្លារ
៣-ឧបាសក **ឡឹម ឌុង** និង ឧបាសិកា **អៀ វ៉ុង** នៅសហរដ្ឋអាមេរិក ថវិកា ចំនួន ១៥.០០០ ដុល្លារ

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

-ឧបាសក **ផាង សារឿម** និង បុត្រ នៅសហរដ្ឋអាមេរិក ថវិកា ចំនួន ៥.០០០ ដុល្លារ

**គ-មេដាយសំរឹទ្ធស្ថាបនាជាតិ :**

១-លោក **វ៉ាយ សាវ៉ាន់** និង ភរិយា ព្រមទាំងបុត្រ ថវិកា ចំនួន ៣.៥០០ ដុល្លារ

២-លោកគ្រូ **កែ សេង** និង ភរិយា ព្រមទាំងបុត្រ ថវិកា ចំនួន ២.០០០ ដុល្លារ

៣-លោកស្រី **គួយ ឃុង** នៅសហរដ្ឋអាមេរិក ថវិកា ចំនួន ១.៥០០ ដុល្លារ

**មាត្រា២៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ,ថ្ងៃទី ២៨ ខែ [illegible] ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**<u>កន្លែងទទួល</u>** ៖

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ ៩៣០ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការតែងតាំង និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹតលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ ០៦ / នស / ៩៤ / ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មករា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក. ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រង ការអនុវត្តការផ្លាស់ប្តូរក្របខ័ណ្ឌឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

**ស ម្រេ ច**

**មាត្រា ១ :** តែងតាំងមន្ត្រីរាជការ នៃក្រសួងសាធារណការ និងដឹកជញ្ជូន ដូចមានរាយនាមខាងក្រោម :

១- លោក **ឆែង សុទិដ្ឋារនោ** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានសាធារណការ

២- លោក **ចាន់ តារា** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានដឹកជញ្ជូន

៣- លោក **ឈុន ប៊ុនតេង** ជាអគ្គាធិការរង នៃអគ្គាធិការដ្ឋាន។

**មាត្រា ២:** ប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ដូចមានរាយនាមខាងក្រោម :

១- លោក **ហុង ស៊ីណារា** ឱ្យបំពេញមុខងារជាអគ្គនាយករង នៃអគ្គនាយកដ្ឋានសាធារណការ
២- លោក **គី សុភាត់** ឱ្យបំពេញមុខងារជាអគ្គនាយករង នៃអគ្គនាយកដ្ឋានសាធារណការ
៣- លោក **ហាន់ សាលី** ឱ្យបំពេញមុខងារជាអគ្គនាយករង នៃអគ្គនាយកដ្ឋានដឹកជញ្ជូន
៤- លោក **នួន សុផល** ឱ្យបំពេញមុខងារជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល
៥- លោក **សន សុខ** ឱ្យបំពេញមុខងារជាអគ្គាធិការរង នៃអគ្គាធិការដ្ឋាន
៦- លោក **គីម បូរី** ឱ្យបំពេញមុខងារជាប្រធាននាយកដ្ឋានស្ពានថ្នល់
៧- លោក **គី លីដា** ឱ្យបំពេញមុខងារជាប្រធាននាយកដ្ឋានគ្រឿងចក្រធំៗ
៨- លោក **ព្រុំ ច័ន្ទសុវណ្ណារី** ឱ្យបំពេញមុខងារជាប្រធាននាយកដ្ឋានសំណង់ផ្លូវអាកាស
៩- លោក **ម៉ក់ ស៊ីដេត** ឱ្យបំពេញមុខងារជាប្រធាននាយកដ្ឋាននាវាជំនួញសមុទ្រ
១០- លោក **សេង សេដ្ឋា** ឱ្យបំពេញមុខងារជាអធិការ
១១- លោក **ហួត សេង** ឱ្យបំពេញមុខងារជាអធិការ
១២- លោក **ទ៉ាន់ ថន** ឱ្យបំពេញមុខងារជាអធិការ
១៣- លោក **គីម តិរុណ** ឱ្យបំពេញមុខងារជាអធិការ
១៤- លោក **ចៅ ខេន** ឱ្យបំពេញមុខងារជាអធិការ
១៥- លោក **ឡាយ ស៊ីដេត** ឱ្យបំពេញមុខងារជាអធិការ
១៦- លោក **ហ៊ី ទីរៈ** ឱ្យបំពេញមុខងារជាអធិការ
១៧- លោក **សុខ សំអុល** ឱ្យបំពេញមុខងារជាអធិការ ។

**មាត្រា ៣:** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៤:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធនិងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ២០០៥*

**ហ៊ុន សែន**

**កន្លែងទទួល:**
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៤*
- *ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ជរដ្ឋាភិបាលកម្ពុជា

ខ ៖ ..៧៥...សសរ

## សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតលេខាធិការដ្ឋានគណៈកម្មាធិការជាតដឹកនាំបញ្ហាការប្រយុទ្ធ និងទប់ស្កាត់អំពើភេរវកម្ម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្តីសំរេចរបស់រាជរដ្ឋាភិបាលលេខ ៨០ សសរ ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៤ ស្តីពីការបង្កើតគណៈកម្មាធិការជាតិ ដឹកនាំ បញ្ហាការប្រយុទ្ធប្រឆាំង និងទប់ស្កាត់អំពើភេរវកម្ម
- តាមសំណើររបស់ប្រធានគណៈកម្មាធិការជាតិ ដឹកនាំ បញ្ហាការប្រយុទ្ធប្រឆាំង និងទប់ស្កាត់អំពើភេរវកម្ម
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១៖** បង្កើត លេខាធិការដ្ឋាន គណៈកម្មាធិការជាតិដឹកនាំបញ្ហាការប្រយុទ្ធប្រឆាំង និងទប់ស្កាត់អំពើភេរវកម្ម ហៅកាត់ លេខាធិការដ្ឋានគណៈកម្មាធិការជាតិប្រឆាំងភេរវកម្ម និងមានអក្សរកាត់ លេខាធិការដ្ឋាន គជបភ ។

**ប្រការ ២៖** លេខាធិការដ្ឋាន គជបភ ជួយការងារប្រធាន គជបភ និង គជបភ អំពីការងារទាំងឡាយសំដៅបង្កើនប្រសិទ្ធភាពការប្រយុទ្ធប្រឆាំង និងទប់ស្កាត់អំពើភេរវកម្មដែលរួមមាន ៖

-កសាង ត្រួតពិនិត្យការអនុវត្តន៍ និងកែសំរួលយុទ្ធសាស្ត្រជាតិនៃការប្រយុទ្ធប្រឆាំងនិងទប់ស្កាត់ភេរវកម្ម

-ប្រមូល និងសរុបពត៌មានចារកម្មពីគ្រប់ស្ថាប័ន និងពត៌មានផ្សេងៗ - វិភាគវាយតំលៃ និងស្នើសុំវិធានការ

-ស្រាវជ្រាវអំពើភេរវកម្ម (ប្រមូលឯកសារ និងពត៌មាន - ចងក្រងឯកសារ និងពត៌មាន រាប់ទាំងឯកសារពត៌មានដែលបានពីបរទេសផង - សួរចម្លើយឈ្លបយកពត៌មានបន្ថែមទៀតពីមុខសញ្ញា ក្នុង និងក្រៅប្រទេស)

-សិក្សារកចំណុចខ្សោយដែលត្រូវបំពេញ និងអ្វីដែលភេរវករអាចធ្វើបានដោយយើងនឹកគិតមិនដល់

-សិក្សាពង្រឹងសមត្ថភាព និងជំនាញក្នុងការប្រយុទ្ធប្រឆាំង និងទប់ស្កាត់ភេរវកម្ម

-បណ្តុះបណ្តាលជំនាញនានា និងបំពាក់បំប៉ន វិធីសាស្ត្រ ការប្រយុទ្ធប្រឆាំង និងទប់ស្កាត់អំពើភេរវកម្ម

-រៀបចំផែនការការពារគោលដៅ (ការពារហេដ្ឋារចនាសម្ព័ន្ធ)- ផែនការសង្គ្រោះ - និងផែនការឃោសនាអប់រំមហាជន - ដឹកនាំការផ្សព្វផ្សាយពត៌មានពេលមានគ្រោះ និងវិបត្តិកើតឡើង

-ជួយរៀបចំកម្លាំងពិសេស កម្លាំងអន្តរាគមន៍ និងកម្លាំងសង្គ្រោះបន្ទាន់ និងបណ្តាញ (ដូចជាបណ្តាញសង្គ្រោះបឋមជាមួយកាកបាទក្រហម) និងការងារជំនាញគាំទ្រនានាផ្សេងទៀត ដូចជាការងារកោសលវិច័យ - ការងារវិភាគគ្រឿងផ្ទុះ - ជាតិគីមី - ជីវសាស្ត្រ - វិទ្យុសកម្ម - នុយក្លេអ៊ែរ - និងមូលដ្ឋានបច្ចេកទេសសំងាត់ឬចំហរនានា

-កសាងធនាគារពត៌មានដោយប្រព័ន្ធកុំព្យូទ័រ និងកសាងមូលដ្ឋានបច្ចេកទេសកុំព្យូទ័រតភ្ជាប់ពត៌មាន ឯកសារ ពីច្រកទ្វារអន្តរជាតិ - ពីស្ថាប័ននានា មកលេខាធិការដ្ឋាន គជបភ

-សិក្សាទិដ្ឋភាពច្បាប់ - អនុសញ្ញា និងសន្ធិសញ្ញាអន្តរជាតិពាក់ព័ន្ធអំពើភេរវកម្ម និងធ្វើរបាយការណ៍នូវការអនុវត្តន៍ អនុសញ្ញា និងសន្ធិសញ្ញាអន្តរជាតិទាំងនោះ ជូនអង្គការសហប្រជាជាតិតាមពេលកំណត់

-ទំនាក់ទំនង និងសហការជាមួយប្រទេសនានាជាទ្វេភាគី និងពហុភាគី ផ្លាស់ប្តូរពត៌មាននិងការវិភាគព្រមទាំងបទពិសោធន៍ និងសំរបសំរួលប្រតិបត្តិការរួមទៅវិញទៅមក

-បំពេញការងារមួយចំនួនទៀត ដែលប្រធាន គជបភ និង គជបក ប្រគល់ឱ្យ

**ប្រការ ៣:** លេខាធិការដ្ឋាន គជបភ ធ្វើសេចក្តីណែនាំលំអិតអំពីរបៀបរបប និងដំណើរការនៃការងារនិមួយៗខាងលើនេះថែមទៀត ដោយមានការពិនិត្យ និងបានការយល់ព្រមពីប្រធាន គជបភ ជាមុនសិន ។

**ប្រការ ៤:** សមាសភាពលេខាធិការដ្ឋាន គជបភ ៖

១- ឯកឧត្តម **ឯម សំអាន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ - សមាជិក គជបក ............................ ប្រធាន
(ទទួលបន្ទុករួម និងទទួលផ្ទាល់ទំនាក់ទំនងសំរបសំរួលការងារស្ថាប័នស៊ីវិល និងឯកជន)

២- ឯកឧត្តម **ហុក ឡុងឌី** អគ្គស្នងការនគរបាលជាតិ - សមាជិក គជបក ............................អនុប្រធាន
(ទទួលបន្ទុករួមលើរាល់កិច្ចការពារហេដ្ឋារចនាសម្ព័ន្ធ)

២- ឯកឧត្តម **ឱម យ៉ិនទៀង** ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី - សមាជិក គជបក ................អនុប្រធាន
(ទទួលបន្ទុកពត៌មាន ស្រាវជ្រាវ បណ្តុះបណ្តាល សំភារៈ បច្ចេកទេស ទំនាក់ទំនង និងសហប្រតិបត្តិការជាតិ អន្តរជាតិ ទ្វេភាគី និងពហុភាគី)

៣- ឯកឧត្តម **មល់ រឿប** ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី - នាយរងសេនាធិការចំរុះ និងជានាយកស្រាវជ្រាវចារកិច្ចអគ្គញ្ញាការដ្ឋានកងយោធពលខេមរភូមិន្ទ ........................................................អនុប្រធាន
(ទទួលបន្ទុកសំរបសំរួលទំនាក់ទំនងការងារយោធា)

៤- ឯកឧត្តម **យុ ស៊ុនឡុង** ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី - អគ្គស្នងការរងនគរបាលជាតិ .......អនុប្រធាន

៥-ឧត្តមសេនីយ៍ឯក **សៅ សុខា** មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស ......................អនុប្រធាន

៦- ឯកឧត្តម **ញៀម សុខារ័ត្ន** ....................................អនុប្រធានប្រចាំការ

៧- ឧត្តមសេនីយ៍ឯក **ស្វ ផន** អគ្គស្នងការរងនគរបាលជាតិ ..........................សមាជិក

៨- ឧត្តមសេនីយ៍ឯក **នេត្រ សាវឿន** អគ្គស្នងការរងនគរបាលជាតិ ..........,.............សមាជិក

៩- ឧត្តមសេនីយ៍ឯក **សុខ ផល** អគ្គស្នងការរងនគរបាលជាតិ ..........................សមាជិក

១០- ឧត្តមសេនីយ៍ឯក **ជា សារ៉ន** មេបញ្ជាការរង និងជានាយសេនាធិការកងទ័ពជើងគោក ...........សមាជិក

១១- ឧត្តមសេនីយ៍ឯក **ហ៊ីង ប៊ុនហៀង** នាយករងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ..............សមាជិក

១២- ឧត្តមសេនីយ៍ទោ **ព្រហ្ម ឌិន** មេបញ្ជាការយោធភូមិភាគពិសេស ..........................សមាជិក

១៣- ឧត្តមសេនីយ៍ទោ **កែវ សាមួន** មេបញ្ជាការយោធភូមិភាគទី ៣..........................សមាជិក

១៤- ឧត្តមសេនីយ៍ទោ **ជា ម៉ន** មេបញ្ជាការយោធភូមិភាគទី ៤..............................សមាជិក

១៥- ឯកឧត្តម **ហេង ពៅ** ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី និងជាស្នងការនគរបាលក្រុងភ្នំពេញ......សមាជិក

១៦- ឧត្តមសេនីយ៍ទោ **មៅ សុផាន់** មេបញ្ជាការកងពលតូចលេខ ៧០..........................សមាជិក

១៧- ឧត្តមសេនីយ៍ត្រី **ចាប ភក្តី** មេបញ្ជាការកងពលតូចទ័ពពិសេសឆ័ត្រយោង ៩១១..................សមាជិក

១៨-តំណាងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ - ធនាគារជាតិនៃកម្ពុជា - ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ - ក្រសួងយុត្តិធម៌ - ក្រសួងសាធារណការនិងដឹកជញ្ជូន - ក្រសួងពាណិជ្ជកម្ម - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ - ក្រសួងសុខាភិបាល - ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ - រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល - គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា - គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ - អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន.................................................................សមាជិក

**ប្រការ ៥:**លេខាធិការដ្ឋានរៀបចំបញ្ជីឈ្មោះជាក់ស្តែងឱ្យតំណាងក្រសួង ស្ថាប័ន ដោយស្នើសុំឱ្យរដ្ឋមន្ត្រី ឬប្រធានស្ថាប័នចាត់ឈ្មោះអ្នកមានសមត្ថកិច្ចមកឱ្យខ្លួន ហើយរៀបចំទាំងតំណាងស្ថាប័នដែលពាក់ព័ន្ធផ្សេងទៀតចូលមកក្នុងក្រុមគាំទ្រការងារ ដើម្បីបំរើឱ្យការធ្វើសៀវភៅផែនការការពារហេដ្ឋារចនាសម្ព័ន្ធ និងការងារវិភាគ ការងារប្រមូលពត៌មាន និងការងារជំនាញផ្សេងៗទៀតដែលចាំបាច់ ។ បញ្ជីឈ្មោះក្រុមគាំទ្រការងារនេះ ត្រូវដាក់ជូនប្រធាន គជបភ ពិនិត្យ និងសំរេច ។

**ប្រការ ៦:** ក្នុងការរៀបចំធ្វើសៀវភៅផែនការតាមគោលដៅដើម្បីការពារហេដ្ឋារចនាសម្ព័ន្ធត្រូវបានចែកចេញជា ៣ ក្រុម:

១-ក្រុមការពារហេដ្ឋារចនាសម្ព័ន្ធទី ១ ហៅកាត់ហេដ្ឋា ១ ប្រគល់ជូនឯកឧត្តម **សុខ ផល** អគ្គស្នងការរងនគរបាលជាតិ ជាប្រធានក្រុមហេដ្ឋា ១ ដឹកនាំការងាររៀបចំសៀវភៅផែនការការពារសំរាប់គោលដៅ ៖

-អគ្គិសនី

-រដ្ឋាករទឹក

-ផ្លូវជាតិ

-ផ្លូវដែក

-អគាររដ្ឋ

-អគារឯកជន

២-ក្រុមការពារហេដ្ឋារចនាសម្ព័ន្ធទី ២ ហៅកាត់ហេដ្ឋា ២ ប្រគល់ជូនឯកឧត្តម **ឃុ ស៊ុនឡុង** ទីប្រឹក្សាផ្ទាល់សម្ដេចនាយករដ្ឋមន្ត្រី និងជាអគ្គស្នងការរងនគរបាលជាតិ ជាប្រធានក្រុមហេដ្ឋា ២ ដឹកនាំការងាររៀបចំសៀវភៅផែនការសំរាប់គោលដៅ ៖

-ព្រលានយន្តហោះ

-កំពង់ផែ

-នាវាចរ (សមុទ្រ និងទន្លេ)

-ពិធីបុណ្យ-អង្គប្រជុំជាតិ-អន្តរជាតិ-គណៈប្រតិភូ

-ស្ថានទូត-កុងសុល-និវេសនដ្ឋានឯកអគ្គរដ្ឋទូត

-សាលាអន្តរជាតិ (ដែលមានកូនសិស្សបរទេសសិក្សា)

៣-ក្រុមការពារហេដ្ឋារចនាសម្ព័ន្ធទី ៣ ហៅកាត់ហេដ្ឋា ៣ ប្រគល់ភារកិច្ចជូនឯកឧត្តម **នេត្រ សាវឿន** ជាប្រធានក្រុមហេដ្ឋា ៣ ដឹកនាំការងារសិក្សាទិដ្ឋភាពច្បាប់ - អនុសញ្ញា និងសន្ធិសញ្ញាអន្តរជាតិពាក់ព័ន្ធអំពើភេរវកម្មនិងធ្វើរបាយកាណ៍នូវការអនុវត្តន៍អនុសញ្ញានិងសន្ធិសញ្ញាអន្តរជាតិទាំងនោះជូនអង្គការសហប្រជាជាតិតាមពេលកំណត់និងទទួលការងាររៀបចំសៀវភៅផែនការ សំរាប់ ៖

-ការប្រឆាំងការលាងលុយកខ្វក់

-ការប្រឆាំងការធ្វើលិខិត ឯកសារក្លែងក្លាយ ការជួញដូរមនុស្ស

-ការប្រឆាំងបទឧក្រិដ្ឋផ្សេងៗទៀត រាប់ទាំងគ្រឿងញៀន

-គីមី ជីវសាស្ត្រ វិទ្យុសកម្ម នុយក្លេអ៊ែរ CBRN និងផែនការអន្តរាគមន៍សង្គ្រោះ រាប់ទាំងផែនការអន្តរាគមន៍សង្គ្រោះក្នុងករណី គីមី ជីវសាស្ត្រ វិទ្យុសកម្ម នុយក្លេអ៊ែរ ទៀតផង

**ប្រការ ៧៖** ក្រុមវិភាគ និងចារកម្មប្រឆាំងភេរវកម្ម ត្រូវបានប្រគល់ភារកិច្ចជូនឯកឧត្តម **ខិម យ៉ិនឡឿង** ទីប្រឹក្សាផ្ទាល់សម្ដេចនាយករដ្ឋមន្ត្រី - សមាជិក គជបភ ជាប្រធានក្រុមវិភាគ និងចារកម្មប្រឆាំងភេរវកម្ម ហើយមានសមាសភាព:

-ក្រុមវិភាគរួមមាន:

១- ឯកឧត្តម **ប្រាក់ សុខុន** ទីប្រឹក្សាផ្ទាល់សម្ដេចនាយករដ្ឋមន្ត្រី - រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក គជបភ ........................................................................................សមាជិក

២- ឧត្តមសេនីយ៍ឯក **ម៉ល់ រឿប** ទីប្រឹក្សាផ្ទាល់សម្ដេចនាយករដ្ឋមន្ត្រី - នាយរងសេនាធិការចំរុះ និងជានាយកស្រាវជ្រាវចារកិច្ចអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ ....................................សមាជិក

៣- ឧត្តមសេនីយ៍ឯក **យូ ស៊ុនឡុង** ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី-អគ្គស្នងការរងនគរបាលជាតិ .សមាជិក

៤- ឯកឧត្តម **អ៊ុច បូរិទ្ធ** រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ .............សមាជិក

៥- ឧត្តមសេនីយ៍ឯក **សៅ សុខា** មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស-សមាជិក គជបក ......សមាជិក

៦- ឧត្តមសេនីយ៍ឯក **នេត្រ សាវឿន** អគ្គស្នងការរងនគរបាលជាតិ ..............................សមាជិក

៧- ឧត្តមសេនីយ៍ឯក **សុខ ផល** អគ្គស្នងការរងនគរបាលជាតិ ........................................សមាជិក

៨ - ឧត្តមសេនីយ៍ឯក **ជុំ ហាក់** មេបញ្ជាការរង កងទ័ពជើងគោក ..................................សមាជិក

៩ - ឯកឧត្តម **ហេង ពៅ** ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី - ស្នងការនគរបាលក្រុងភ្នំពេញ ........សមាជិក

១០ - ឧត្តមសេនីយ៍ឯក **គន្ធ សំអឿន** ប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ .........................សមាជិក

១១- ឧត្តមសេនីយ៍ត្រី **ស៊ិន សុផាន្នី** នាយសេនាធិការរង និងជានាយការិយាល័យកណ្តាលស្រាវជ្រាវកងរាជអាវុធហត្ថលើផ្ទៃប្រទេស .......................................................................សមាជិក

១២- ឧត្តមសេនីយ៍ត្រី **យ៉ៅ គីមអ៊ី** មេបញ្ជាការកងរាជអាវុធហត្ថក្រុងភ្នំពេញ ........................សមាជិក

-ក្រុមចារកម្មរួមមាន:

១- ឧត្តមសេនីយ៍ឯក **គន្ធ សំអឿន** ប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ ............................សមាជិក

២- ឧត្តមសេនីយ៍ទោ **ប៊ិត គីមហុង** ប្រធាននាយកដ្ឋានប្រឆាំងភេរវកម្ម ...............................សមាជិក

៣- ឧត្តមសេនីយ៍ទោ **ស៊ំរិត ហ៊ុន** នាយការិយាល័យទី ២ កងទ័ពជើងគោក .........................សមាជិក

៤- ឧត្តមសេនីយ៍ត្រី **ស៊ិន សុផាន្នី** នាយសេនាធិការរង និងជានាយការិយាល័យកណ្តាលស្រាវជ្រាវកងរាជអាវុធហត្ថលើផ្ទៃប្រទេស ...........................................................................សមាជិក

៥- ឧត្តមសេនីយ៍ត្រី **ឆៃ ស៊ីណារិទ្ធ** ប្រធាននាយកដ្ឋានពត៌មានទូទៅ ...............................សមាជិក

៦- ឧត្តមសេនីយ៍ត្រី **គៀត ច័ន្ទថារិទ្ធ** ប្រធាននាយកដ្ឋានជនបរទេស ................................សមាជិក

៧- ឧត្តមសេនីយ៍ត្រី **មាស ផេន** នាយរងនាយកដ្ឋានស្រាវជ្រាវចារកិច្ច អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ ........................................................................................សមាជិក

៨- ឧត្តមសេនីយ៍ត្រី **សិទ្ធិ សាវឿន** នាយរងនាយកដ្ឋានស្រាវជ្រាវចារកិច្ច អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ ..........................................................................................សមាជិក

៩- ឧត្តមសេនីយ៍ត្រី **គីម នាន** ជំនួយការសម្តេចនាយករដ្ឋមន្ត្រី ....................................សមាជិក

១០- វរៈសេនិយ៍ឯក **ហ៊ី ព្រូ** ស្នងការរងនគរបាលក្រុងភ្នំពេញ ...........................................សមាជិក

១១- វរៈនារីឯក **មី ឌីណា** នាយការិយាល័យទី ២ កងទ័ពជើងទឹក ....................................សមាជិក

១២-វរៈសេនិយ៍ឯក **ពៅ ពិចិត្រ** នាយក្រុមប្រតិបត្តិការក្នុងប្រទេសនាយកដ្ឋានស្រាវជ្រាវចារកិច្ចអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ ..................................................................................សមាជិក

១៣-វរៈសេនិយ៍ឯក **ស៊ឹម ហុង** មេបញ្ជាការរងកងរាជអាវុធហត្ថក្រុងភ្នំពេញ ..........................សមាជិក

១៤-វរៈសេនិយត្រី ម៉ាក់ សុជាវី សមាជិកក្រុមលេខាសម្ដេចនាយករដ្ឋមន្ត្រី ..........................សមាជិក

**ប្រការ៨**:មន្ត្រី បុគ្គលិកបំរើការក្នុងលេខាធិការដ្ឋាន សុទ្ធតែជាអ្នកដែលមានក្របខ័ណ្ឌស្រាប់ លើកលែងតែមានតំរូវការអ្នកជំនាញដូចជាកុំព្យូទ័រ ឬជំនាញផ្សេងៗ ទើបអនុញ្ញាតស្នើសុំក្របខ័ណ្ឌថ្មី ដោយបញ្ចូលមកក្នុងក្របខ័ណ្ឌទីស្ដីការគណៈរដ្ឋមន្ត្រី ។

**ប្រការ៩**:លេខាធិការដ្ឋាន គជបភ មានត្រា និងថវិកាដោយឡែករបស់ខ្លួន ។ ក្នុងពេលថវិកាដោយឡែករបស់លេខាធិការដ្ឋាន គជបភ មិនទាន់បានទទួលការអនុម័ត រាល់ចំណាយដំណើរការនៃលេខាធិការដ្ឋាន គជបភ ជាបន្ទុករបស់ទីស្ដីការគណៈរដ្ឋមន្ត្រី ។

ទីស្ដីការគណៈរដ្ឋមន្ត្រី និងក្រសួងមហាផ្ទៃមានភារកិច្ចរៀបចំអគារសំរាប់ធ្វើជាលេខាធិការដ្ឋាន និងសំរាប់ធ្វើជាមូលដ្ឋាននានារបស់លេខាធិការដ្ឋាន ។

**ប្រការ ១០**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រី ប្រធានស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដែលមានឈ្មោះនៅក្នុងប្រការ ៤ - ប្រការ ៦ និងប្រការ ៧ ត្រូវអនុវត្តសេចក្ដីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់តាំងពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

-ក្រសួងបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

-ក្រសួងការពារជាតិ

-ក្រសួងមហាផ្ទៃ

-អគ្គលេខាធិការដ្ឋានរដ្ឋាភិបាល

-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្ដេច និងឯកឧត្តម ឧបនាយករដ្ឋមន្ត្រី

-ដូចប្រការ ១០

-កាលប្បវត្តិ - ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣៦ សសរ

## សេចក្ដីសម្រេច
## ស្ដីពី
## ការកែសម្រួលសមាសភាពនៃក្រុមការងារសម្រាប់បំភ្លឺ
## ទៅនឹងមតិជំទាស់ជាមួយនយោបាយដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា

----------

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតទីស្ដីការគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្ដីសម្រេចលេខ ១៤ សសរ ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០០៥ ស្ដីពីការបង្កើតក្រុមការងារសម្រាប់បំភ្លឺទៅនឹងមតិជំទាស់ជាមួយនយោបាយដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសភាពការណ៍ចាំបាច់

## សម្រេច

**ប្រការ១ :** ត្រូវបានកែសម្រួលសមាសភាពប្រការ១ នៃសេចក្ដីសម្រេចលេខ១៤ សសរ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០០៥ ស្ដីពីការបង្កើតក្រុមការងារសម្រាប់បំភ្លឺទៅនឹងមតិជំទាស់ជាមួយនយោបាយដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ដូចតទៅ :

-ឯកឧត្ដម **នុត សារអាន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ជាអនុប្រធាន ជំនួសឯកឧត្ដម **ព្រុំ សុខា**

-ឯកឧត្ដម **ឡាយ សុខា** ទីប្រឹក្សារាជរដ្ឋាភិបាល ជាសមាជិក ។

**ប្រការ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី ក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះ-បណ្ដាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវទទួលអនុវត្តសេចក្ដីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២[illegible] ខែ កក្កដា ឆ្នាំ ២០០៥

ហ៊ុន សែន

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច និងឯកឧត្ដមឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចប្រការ ២
- ឯកសារ កាលប្បវត្តិ

\Vns change.doc

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០៦. សារាចរ

## សារាចរណែនាំ

## ស្តីពី

## ការអនុវត្តគំរោងរបស់អង្គការពលកម្មអន្តរជាតិ ដើម្បីធ្វើឱ្យប្រសើរឡើងដល់រោងចក្រកម្ពុជា ក្នុងវិស័យវាយនភ័ណ្ឌ និងសំលៀកបំពាក់

ក្នុងស្មារតីលើកកំពស់ និងការពារសិទ្ធិកម្មករ និងនិយោជិតក្នុងព្រះរាជាណាចក្រកម្ពុជា ឱ្យកាន់តែមានលក្ខណៈល្អប្រសើរស្របតាមស្តង់ដាររបស់អង្គការពលកម្មអន្តរជាតិ (ILO) រាជរដ្ឋាភិបាលកម្ពុជាដាក់ចេញនូវសេចក្តីណែនាំ ដូចខាងក្រោម :

**ទី១:** អនុវត្តគោលនយោបាយឯកតោភាគីជាមូលដ្ឋានរបស់រាជរដ្ឋាភិបាលកម្ពុជា ដោយផ្សារភ្ជាប់លក្ខខ័ណ្ឌការងារក្នុងវិស័យវាយនភ័ណ្ឌ និងសំលៀកបំពាក់នៅកម្ពុជា ជាមួយពាណិជ្ជកម្មអន្តរជាតិ។

**ទី២:** អនុវត្តគំរោងដែលរៀបចំថ្មីរបស់អង្គការពលកម្មអន្តរជាតិដើម្បីធ្វើឱ្យប្រសើរឡើងដល់រោងចក្រកម្ពុជា ក្នុងគោលបំណងបន្តលើកកំពស់លក្ខខ័ណ្ឌការងារក្នុងវិស័យវាយនភ័ណ្ឌ និងសំលៀកបំពាក់ រួមបញ្ចូលទាំងការគោរពស្តង់ដារការងារដែលទទួលស្គាល់ជាអន្តរជាតិ តាមរយៈការអនុវត្តច្បាប់ស្តីពីការងាររបស់ព្រះរាជាណាចក្រកម្ពុជា។ ក្នុងការអនុវត្តគំរោងនេះ កម្ពុជានឹងធានាថា ច្បាប់ស្តីពីការងារ និងបទដ្ឋានផ្សេងៗ ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព ហើយបង្កើតឱ្យមាននូវបរិយាកាសការងារប្រកបដោយផលិតភាព និងគុណភាពខ្ពស់ ព្រមទាំងជំរុញឱ្យមានតម្លាភាពក្នុងការអនុវត្តច្បាប់ស្តីពីការងារ ដើម្បីឱ្យមានភាពរលូនក្នុងការពង្រឹងប្រសិទ្ធភាពច្បាប់ និងបទដ្ឋានការងារដែលមានស្រាប់ និងលើកស្ទួយសិទ្ធិការងារទូទៅ ដូចមានចែងនៅក្នុងច្បាប់ស្តីពីការងារនៃព្រះរាជាណាចក្រកម្ពុជា។

**ទី៣:** គ្រប់រោងចក្រវាយនភ័ណ្ឌ និងសំលៀកបំពាក់ ព្រមទាំងអ្នកម៉ៅការផលិតបន្ត ត្រូវចុះបញ្ជីនៅការិយាល័យគំរោងរបស់អង្គការពលកម្មអន្តរជាតិដើម្បីធ្វើឱ្យប្រសើរឡើងដល់រោងចក្រកម្ពុជា ហើយត្រូវរួមគ្នាគោរពច្បាប់ស្តីពីការងារនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីទទួលបានសិទ្ធិស្របច្បាប់សំរាប់ការនាំចេញ ។

**ទី៤:** រោងចក្រវាយនភ័ណ្ឌ និងសំលៀកបំពាក់ទាំងឡាយ ដែលបានចុះបញ្ជីនៅការិយាល័យរបស់អង្គការពលកម្មអន្តរជាតិដើម្បីធ្វើឱ្យប្រសើរឡើងដល់រោងចក្រកម្ពុជា មានសិទ្ធិស្នើសុំវិញ្ញាបនប័ត្រប្រភពដើមទំនិញ និងឯកសារនាំចេញផ្សេងៗពីក្រសួងពាណិជ្ជកម្ម ក្រោយពីបានចុះបញ្ជីប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ។

**ទី៥:** ក្នុងករណីរោងចក្រវាយនភ័ណ្ឌ និងសំលៀកបំពាក់ទាំងឡាយ ដែលមិនបានចុះបញ្ជីជាមួយគំរោងរបស់អង្គការពលកម្មអន្តរជាតិដើម្បីធ្វើឱ្យប្រសើរឡើងដល់រោងចក្រកម្ពុជា នឹងត្រូវលុបចេញពីបញ្ជីប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ហើយនឹងមិនអនុញ្ញាតឱ្យធ្វើការនាំចេញឡើយ ។

**ទី៦:** រោងចក្រវាយនភ័ណ្ឌ និងសំលៀកបំពាក់ទាំងឡាយ ដែលមិនព្រមអនុវត្តតាមច្បាប់ស្តីពីការងារ និងបទដ្ឋានគតិយុត្តិជាធរមាន នឹងត្រូវទទួលការពិន័យរដ្ឋបាលពីក្រសួងពាណិជ្ជកម្ម ជាបួនតំណាក់កាលដូចខាងក្រោម :

១- ត្រូវទទួលលិខិតព្រមានពីក្រសួងពាណិជ្ជកម្ម នៅពេលដែលពិនិត្យរបាយការណ៍ឃើញថា មានការរំលោភច្បាប់ស្តីពីការងារ និងបទដ្ឋានគតិយុត្តិធ្ងន់ធ្ងរ ដោយមានការបញ្ជាក់ពីក្រុមឃ្លាំមើលគំរោងរបស់អង្គការពលកម្មអន្តរជាតិ ដើម្បីធ្វើឱ្យប្រសើរឡើងដល់រោងចក្រកម្ពុជា ដែលស្របនឹងរបាយការណ៍របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

២- ហាមនាំចេញផលិតផលវាយនភ័ណ្ឌ និងសំលៀកបំពាក់ ក្នុងរយៈពេល ១សប្តាហ៍ ចំពោះរោងចក្រទាំងឡាយណាដែលមានកំហុស ហើយពុំបានកែប្រែក្នុងអំឡុងពេល ១សប្តាហ៍ បន្ទាប់ពីបានទទួលលិខិតព្រមានរួច ។

៣- ហាមនាំចេញផលិតផលវាយនភ័ណ្ឌ និងសំលៀកបំពាក់រយៈពេល ៣ខែ ចំពោះរោងចក្រទាំងឡាយណាដែលមានកំហុស ហើយពុំបានកែប្រែក្នុងអំឡុងពេល ២សប្តាហ៍ បន្ទាប់ពីបានទទួលលិខិតព្រមានរួច ។

៤- ហាមនាំចេញផលិតផលវាយនភ័ណ្ឌ និងសំលៀកបំពាក់ជាស្ថាពរ ចំពោះរោងចក្រទាំងឡាយណាដែលមានកំហុស ហើយពុំបានកែប្រែក្នុងអំឡុងពេល ៣ខែ បន្ទាប់ពីបានទទួលលិខិតព្រមានរួច ។

**ទី៧:** ក្នុងករណីដែលមានការហាមឃាត់ ចំពោះរោងចក្រដែលមានកំហុសដូចបានរៀបរាប់ខាងលើ គ្រប់ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចនៅតាមច្រកទ្វារព្រំដែនទាំងអស់ ត្រូវសហការគ្នាឱ្យបានល្អជាមួយក្រសួងពាណិជ្ជកម្ម ក្នុងការអនុវត្តបំរាមនេះ ។

ទទួលបានសារាចរណែនាំនេះ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដីគ្រប់ខេត្ត-ក្រុង ត្រូវចាត់តាំងអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៥

ហ៊ុន សែន

**ចំលងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- គ្រប់ស្ថានឯកអគ្គរដ្ឋទូតកម្ពុជា ប្រចាំនៅបរទេស
- គ្រប់ស្ថានទូតបរទេសប្រចាំនៅព្រះរាជាណាចក្រកម្ពុជា
  "ដើម្បីជូនជ្រាប"
- ការិយាល័យធ្វើឱ្យប្រសើរឡើងដល់រោងចក្រកម្ពុជារបស់អង្គការ ILO
- សមាគមរោងចក្រកាត់ដេរកម្ពុជា
- ដូចមាត្រាទី៣
  "ដើម្បីអនុវត្ត"
- រាជកិច្ច ទូរទស្សន៍ និងវិទ្យុជាតិ
  "ដើម្បីផ្សព្វផ្សាយ"
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**ក្រសួងមហាផ្ទៃ**

លេខ : ៨៩៧ ប្រ.ក

**ប្រកាស**

**ស្តីពី**

**ការលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ**

**********

**ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាទូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណបក្សនយោបាយ

-បានឃើញអនុក្រឹត្យ លេខ១៦អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ

-បានឃើញប្រកាសស្តីពីការចុះឈ្មោះក្នុងបញ្ជីគណបក្សនយោបាយលេខ០៩២ប្រក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩៩៨

-តាមសំណើ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៥ របស់លោកបណ្ឌិត ប៊ិត ស៊ាងលីម ប្រធានគណបក្សសាធារណរដ្ឋសេរីអក្សរកាត់ ( គ.ស.ស ) ។

**ស ំ រេ ច**

ប្រការ១ : លុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃ **គណបក្សសាធារណរដ្ឋសេរី** ដែលមានទីស្នាក់ការកណ្តាលតាំងនៅ ផ្ទះភូមិគ្រឹះសង់ថ្មី ផ្លូវយោធពលខេមរៈភូមិន្ទ ភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

ប្រការ២ : អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គាធិការ នៃអគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល និងគណបក្សសាធារណរដ្ឋសេរី ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខា និងឡាយព្រះហស្តលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ២០០៥

ស ខេង នរោត្តម.សិរីវុឌ្ឍ

**<u>កន្លែងទទួល</u> :**

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងយុត្តិធម៌
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
"ដើម្បីជូនជ្រាប"
-គ្រប់សាលាខេត្ត-ក្រុង
-ដូចប្រការ២
"ដើម្បីអនុវត្ត"
-រាជកិច្ច✓
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១៥៣៥ ពណ.នគក

ភ្នំពេញថ្ងៃទី ០៤ ខែកក្កដា ឆ្នាំ ២០០៥

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ជេ. ស៊ី. ធី**

**J . C . T Co.,Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 7809/05P ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០៥

មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **សោភាន់ ចែត្រា**

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ៤ Eo ផ្លូវលេខ ១៧២ សង្កាត់ផ្សារថ្មីទី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម :
- -ទេសចរណ៍ : សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន រមណីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត ទីភ្នាក់ងារទេសចរណ៍ លក់សំបុត្រយន្តហោះ នាំភ្ញៀវទេសចរដើរកំសាន្ត
- -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
- -ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
- -ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
- -ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
- -មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
- -បើកសាលារៀន
- -សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
- -សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
- -សេវាផ្សាយពាណិជ្ជកម្ម
- -បោះពុម្ពផ្សាយ
- -ផលិតខ្សែភាពយន្ត វីដេអូ CD
- -ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស និងការដឹកជញ្ជូន និងចែកចាយទំនិញ
- -សាងសង់ ជួសជុល អគារ ស្ពាន ផ្លូវ

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

គីម_ស៊ីថន

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១៤៤០ ពណ.នគក

ភ្នំពេញថ្ងៃទី ០៤ ខែកក្កដាឆ្នាំ ២០០៥

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

